គម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ
ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

# សៀវភៅណែនាំស្តីពី
# ការចិញ្ចឹមមាន់ពូជក្នុងស្រុក សម្រាប់ភ្ញាស់យកកូន
# យកសាច់ជាលក្ខណៈពាណិជ្ជកម្មខ្នាតតូច ក្នុងជួរកសិករ








ឆ្នាំ២០២០(រក្សាសិទ្ធ)


បណ្ឌិត **សួន សុធឿន** **(SUON SOTHOEUN)**
បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)

# មាតិកា


| | | |
|---|---|---|
| **អារម្ភកថា**........................................ | | V |
| **សេចក្តីថ្លែងអំណរគុណ**........................................ | | IX |
| ១ | **ហេតុអ្វីត្រូវចាប់យកមុខរបរចិញ្ចឹមមាន់ពូជក្នុងស្រុក?**............ | ១ |
| ២ | **បច្ចេកទេសចិញ្ចឹម**........................................ | ៣ |
| ២.១ | ការជ្រើសរើសទីកន្លែងចិញ្ចឹមមាន់........................ | ៣ |
| ២.២ | ការរៀបចំរោងនិងទ្រុងសម្រាប់ចិញ្ចឹមមាន់........................ | ៣ |
| ២.២.១ | រោងនិងទ្រុងចិញ្ចឹមមាន់សម្រាប់ភ្ញាស់លក់កូន............ | ៣ |
| | ក/ រោងនិងទ្រុងមេ-បាសម្រាប់ឱ្យមាន់ពង................ | ៣ |
| | ខ/ ទ្រុងសម្រាប់ថែទាំកូនមាន់ទើបញាស់អាយុពី១-៧ថ្ងៃ...... | ៧ |
| | គ/ ទ្រុងកូនមាន់អាយុពី៧-២១ថ្ងៃឬ៣០ថ្ងៃ................ | ៨ |
| ២.២.២ | ទ្រុងចិញ្ចឹមមាន់សម្រាប់ភ្ញាស់កូនដើម្បីចិញ្ចឹមមាន់សាច់...... | ៨ |
| | ក/ ទ្រុងមាន់ចិញ្ចឹមយកសាច់........................ | ៩ |
| ២.៣ | ឧបករណ៍និងសម្ភារៈចាំបាច់សម្រាប់ចិញ្ចឹមនិងភ្ញាស់......... | ១៥ |
| | ក/ ទូភ្ញាស់........................................ | ១៥ |
| | ខ/ ម៉ាស៊ីនកិនចំណី........................................ | ១៧ |
| | គ/ ម៉ាស៊ីនហាន់បន្លែ........................................ | ១៧ |
| | ឃ/ ប្រដាប់ដាក់ចំណីឬស្នូកចំណី........................ | ១៨ |
| | ង/ ប្រដាប់ដាក់ទឹកឬក្បាលបឺត........................ | ១៨ |
| | ច/ ឆ្នើរនិងសម្បុក........................................ | ១៩ |
| | ឆ/ ភ្លើងបំភ្លឺនិងប្រដាប់វាស់ស៊ីតណ្ហភាព................ | ២០ |
| ២.៤ | ការជ្រើសរើសពូជមាន់សម្រាប់ចិញ្ចឹម........................ | ២១ |
| | ក/ មេសម្រាប់ធ្វើពូជ........................................ | ២១ |




បណ្ឌិត **សួន សុធឿន** បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)

| | | |
|---|---|---|
| | ខ/ បាសម្រាប់ធ្វើពូជ................................ | ២១ |
| | គ/ ការជ្រើសរើសកូនមាន់សម្រាប់បំប៉នយកសាច់.......... | ២២ |
| ២.៥ | ចំណី ការផ្សំចំណី ទឹក និងការផ្តល់ចំណីនិងទឹក.......... | ២៤ |
| ២.៥.១ | ចំណី................................................ | ២៤ |
| | ក/ ចំណីផ្តល់នូវថាមពល................................ | ២៤ |
| | ខ/ ចំណីផ្តល់នូវប្រូតេអ៊ីន (ជាតិសាច់)...................... | ២៤ |
| | គ/ វីតាមីន.............................................. | ២៤ |
| | ឃ/ ចំណីផ្តល់នូវជាតិរ៉ែ...................................... | ២៤ |
| ២.៥.២ | ការផ្សំចំណី........................................... | ២៥ |
| | ក/ ចំណីកូនមាន់ (អាយុ១-៣០ថ្ងៃ)......................... | ២៥ |
| | ខ/ ចំណីសម្រាប់មាន់ធំនិងមេមាន់........................ | ២៦ |
| ២.៥.៣ | ការផ្តល់ចំណីនិងទឹក (របបអាហារ)......................... | ២៧ |
| | ក/ ការផ្តល់ចំណីនិងទឹកសម្រាប់កូនមាន់អាយុ១-៣០ថ្ងៃ)....... | ២៧ |
| | ខ/ ការផ្តល់ចំណីមាន់ជំទង់ (អាយុ៣០-៦០ថ្ងៃ)................ | ២៧ |
| | គ/ ការផ្តល់ចំណីមាន់ធំ (អាយុ៦០-១២០ថ្ងៃ)................. | ២៨ |
| | ឃ/ ការផ្តល់ចំណីសម្រាប់មេមាន់និងបា..................... | ២៨ |
| ២.៦ | ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់និងការភ្ញាស់ស៊ុត............ | ២៩ |
| | ក/ ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់......................... | ២៩ |
| | ខ/ ការសម្អាតនិងថែរក្សាស៊ុតដើម្បីភ្ញាស់...................... | ៣០ |
| | គ/ ការភ្ញាស់ស៊ុត........................................... | ៣០ |
| ២.៧ | ការថែទាំកូនមាន់អាយុ១-៣០ថ្ងៃ.............................. | ៣២ |
| ២.៨ | ការថែទាំទូទៅ ការគ្រប់គ្រងការចិញ្ចឹម អនាម័យ និងជីវសុវត្ថិភាព........................................ | ៣២ |



បណ្ឌិត **សួន សុះធៀន** បណ្ឌិតវិទ្យាសាស្ត្រពេទ្យសត្វ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)

| | | |
|---|---|---|
| ២.៩ | ការបង្ការនិងការពារជំងឺ.................................... | ៣៣ |
| ២.៩.១ | ជីវសុវត្ថិភាព.................................... | ៣៣ |
| ២.៩.២ | ជំងឺសំខាន់ៗដែលជួបប្រទះ.................................... | ៣៥ |
| ២.៩.២.១ | ជំងឺអាសន្នរោគ (Fowl Cholera/Avian Pasteurellosis)............ | ៣៥ |
| ២.៩.២.២ | ជំងឺញូកាស (Newcastle Disease).................................... | ៣៥ |
| ២.៩.២.៣ | ជំងឺអុត (Fowl Pox).................................... | ៣៦ |
| ២.៩.២.៤ | ជំងឺផ្ដាសាយបក្សី (Avian Influenza/Bird Flu)...................... | ៣៧ |
| ២.៩.២.៥ | ជំងឺបង្កដោយព្រូនមូល (Ascaridiosis)............................ | ៣៨ |
| ២.៩.២.៦ | បរាសិតខាងក្រៅ(ស្រមើល ចៃ).................................... | ៣៨ |
| ២.៩.២.៧ | ជំងឺផ្សេងៗទៀត.................................... | ៤០ |
| | ជំងឺរាគឈាម (Coccidiosis).................................... | ៤០ |
| | ជំងឺរលាកផ្លូវដង្ហើម (Chronic Respiratory Disease)............ | ៤១ |
| | ជំងឺរាគស (Salmonellosis).................................... | ៤១ |
| ៣ | ការរៀបចំអាជីវកម្មចិញ្ចឹមមាន់ខ្នាតតូច.................................... | ៤៣ |
| ៣.១ | ការសម្រេចចិត្តក្នុងការធ្វើអាជីវកម្មចិញ្ចឹមមាន់................ | ៤៣ |
| ៣.២ | ការវិនិយោគ.................................... | ៤៤ |
| ៣.៣ | ការរៀនសូត្របច្ចេកទេសនិងការគ្រប់គ្រង.................................... | ៤៤ |
| ៣.៤ | ការប្រតិបត្តតាមបច្ចេកទេសនិងបទដ្ឋាននៃសៀវភៅនេះ..... | ៤៥ |
| ៣.៥ | ការគ្រប់គ្រងហិរញ្ញវត្ថុលើការចិញ្ចឹមមាន់.................................... | ៤៥ |
| ៣.៥.១ | ការកត់ត្រាចំណាយ ចំណូល និងការគ្រប់គ្រង ហិរញ្ញវត្ថុ.................................... | ៤៥ |
| ៣.៥.២ | ការវិភាគសេដ្ឋកិច្ច.................................... | ៤៦ |
| | **ឯកសារស្រាវជ្រាវ**.................................... | ៤៧ |

# អារម្ភកថា

សៀវភៅណែនាំស្តីពីការចិញ្ចឹមមាន់ពូជក្នុងស្រុកសម្រាប់ភ្ញាស់យកកូន និង/ឬយកសាច់ ជាលក្ខណៈពាណិជ្ជកម្មខ្នាតតូចក្នុងជួរកសិករ ត្រូវបានរៀបចំនិងតាក់តែងឡើង ដើម្បីបង្កើតមុខរបរនិងប្រាក់ចំណូលដល់កសិករ ដល់ប្រជាពលរដ្ឋខ្មែរដើម្បីរកប្រាក់កាស ប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ សម្រាប់ផ្គត់ផ្គង់តម្រូវការដែលចេះតែកើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ខណៈពេលដែលសេដ្ឋកិច្ចរបស់ប្រទេសកំពុងមានការរីកចម្រើនលូតលាស់។ ក្នុងសម័យកាលនៃជំងឺកូវិដ-១៩ សៀវភៅនេះនឹងជួយបង្កើតមុខរបរ និងបង្កើតប្រាក់ចំណូល ដល់បងប្អូនប្រជាពលរដ្ឋខ្មែរដែលឈប់ពីបម្រើការងារនៅរោងចក្រ និងជាពិសេស ចំពោះជនចំណាកស្រុកដែលត្រូវបានត្រឡប់មកកម្ពុជាវិញ ហើយគ្មានការងារធ្វើ គ្មានមុខរបរ គ្មានប្រាក់ចំណូល ក្នុងពេលដែលពិភពលោកបាននឹងកំពុងរងគ្រោះ ដោយសារការឆ្លងរាលដាលជាសាកល និងមហាប្រល័យនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងក្លាដល់សេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចពិភពលោក។

សៀវភៅនេះក៏លើកទឹកចិត្ត និងជម្រុញកសិករ ប្រជាពលរដ្ឋខ្មែរឱ្យចិញ្ចឹមមាន់ពូជក្នុងស្រុកដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក។ ប្រទេសកម្ពុជាត្រូវការម្ហូបអាហារដែលមានប្រភពពីសត្វកាន់តែច្រើនឡើងៗ។ ជំរឿនកសិកកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣(២០១៥) ក៏បានបង្ហាញថា ចំនួនថ្ងៃជាមធ្យមក្នុងមួយសប្តាហ៍ដែលគ្រួសារកសិកម្មប្រើប្រាស់សាច់និងផលិតផលសាច់មាន៣.៨ថ្ងៃ ច្រើនជាងការបរិភោគត្រីដែលមានតែ៣.៥ថ្ងៃ។ តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា នៅប្រទេសកម្ពុជា មានតម្រូវការសាច់សត្វប្រមាណ២៨៦ ០០០តោន នៅឆ្នាំ២០១៥ និងកើនឡើងដល់៣០០ ០០០តោននៅឆ្នាំ២០២០ ក្នុងនោះសាច់មាន់-ទា ប្រមាណ

៦១ ០០០តោន។ តម្រូវការនេះចេះតែកើនឡើងៗដែលចាំបាច់ត្រូវជំរុញឱ្យការផលិតការចិញ្ចឹមមាន់ពូជក្នុងស្រុក ដែលមានគុណភាពល្អ និងមានសុវត្ថិភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ បើពុំដូច្នោះទេ កម្ពុជាត្រូវប្រឈមនឹងការនាំចូលពីបរទេស ការលួចរត់ពន្ធចូលនូវមាន់រស់ ឬសាច់មាន់ដែលផលិតផលទាំងនោះអាចមានតម្លៃថោកជាង ប៉ះពាល់ដល់ផលិតកម្មក្នុងស្រុក និងអាចមានហានិភ័យខ្ពស់ផ្នែកសុខភាពសាធារណៈ។

ខ្ញុំបានចំណាយពេលច្រើនបង្គួរដើម្បីរៀបរៀងសៀវភៅនេះ ដែលបោះពុម្ពលើកដំបូងនៅឆ្នាំ២០១៧ ចំនួន១៥០០ក្បាល បោះពុម្ពលើកទី២ឆ្នាំ២០១៨-៣០០០ក្បាល និងលើកទី៣ឆ្នាំ២០២០-១០០០ក្បាល ដោយមានការសម្រួលខ្លះៗពីការបោះពុម្ពលើកមុន ដោយសារមានទិន្នន័យថ្មីៗបន្ថែមពីការស្រាវជ្រាវ-វិភាគពីសំណាក់កសិករដែលបានអនុវត្តសាកល្បងក្នុងគម្រោងជាច្រើនឆ្នាំនិងបច្ចេកទេសថ្មីៗ។ សៀវភៅនេះផ្សំពីទ្រឹស្តី បច្ចេកទេសវិទ្យាសាស្ត្រ បូកផ្សំជាមួយការអនុវត្តជាក់ស្តែង ដែលត្រូវបានអនុវត្តសាកល្បងជាមួយកសិករ (demonstration trials among famers) ដើម្បីឱ្យប្រាកដថាទ្រឹស្តីនិងការគិតគូរដែលយកមកប្រើប្រាស់នេះ អាចអនុវត្តបានក្នុងស្ថានភាពនៅកម្ពុជា ដោយគិតគូរពីបញ្ហាតម្លៃនិងទីផ្សារ ការចំណាយ-ចំណូល (costs and benefits) និងការប្រកួតប្រជែងពីអ្នកផលិតធំៗ ជាពិសេស ពីលំហូរមាន់រស់និងសាច់មាន់ពីបរទេស។

សៀវភៅនេះណែនាំឱ្យចិញ្ចឹមមាន់ពូជក្នុងស្រុកនិងចាប់ផ្តើមអាជីវកម្មដំបូង:

- ចិញ្ចឹមមេចំនួន៩០ក្បាល និងមាន់ឈ្មោលសម្រាប់ធ្វើបាចំនួន១៥ក្បាល សរុបមក ផ្តើមអាជីវកម្មជាមួយមាន់ចំនួន១០៥ក្បាល។
- អាយុមាន់ដែលយកមកធ្វើជាមេនិងបា (អាចទិញពីប្រភពដែលគ្មានជំងឺជាពូជល្អ) អាយុពី៣-៤ខែ។ ទិញកូនមកចិញ្ចឹមក៏បាន ប៉ុន្តែត្រូវការពេល

វេលាច្រើនទម្រាំមាន់ពងជាលើកដំបូង និងកូនមាន់មួយចំនួនអាចងាប់ ឬត្រូវជម្រុះចោល ដូចនេះ ចំនួនពូជដែលទិញចូលនៅគ្រាដំបូងនេះ ត្រូវមានចំនួនច្រើនជាងផែនការ

- ការវិនិយោគអស់ទឹកប្រាក់ចំនួន១៤ ០០០ ០០០រៀល (៣ ៥០០ដុល្លារអាមេរិក) សម្រាប់ការចិញ្ចឹម ដូចជារោង ទ្រុង ឧបករណ៍ សម្ភារៈ ចំណីវ៉ាក់សាំង។ល។ ប៉ុន្តែនៅមិនគិតដល់ការចំណាយលើការសិក្សារៀនសូត្របច្ចេកទេសចិញ្ចឹម ការថែទាំ ការបង្ការ ការការពារជំងឺនិងការគ្រប់គ្រងអាជីវកម្មដែលខ្ញុំយល់ថា សេវាទាំងនេះត្រូវផ្តល់ដោយអង្គភាពផលិតកម្មនិងបសុព្យាបាល ឬអង្គការនានាដែលធ្វើការងារទាក់ទងការចិញ្ចឹមសត្វ។
- លទ្ធផលដែលនឹងទទួលបាន (ករណីអនុវត្តបានតាមការណែនាំ):

√កូនមាន់ច្រើនជាង៥០០ក្បាល/ខែ ឬមាន់សាច់ទម្ងន់១.៥០-១.៧០គក្រ ចំនួន១១២ក្បាល/ខែ(១៦៨គក្រ-១៩០គក្រ)

√ចំណូលច្រើនជាង១ ៨០០ ០០០រៀល ឬបានប្រាក់ចំណេញច្រើនជាង១ ២០០ ០០០រៀល/ខែ(៣០០ដុល្លារអាមេរិក)

√មានកសិករក្នុងគម្រោងជាមួយដើមទុននិងការបណ្តុះបណ្តាលនេះ បានប្រែក្លាយពីកសិករចិញ្ចឹម-ភ្ញាស់ជាលក្ខណៈពាណិជ្ជកម្មខ្នាតតូចទៅកសាងជាបណ្តុំកសិករផលិត ដែលមានចំណូលខ្ពស់ ហើយអាចក្លាយទៅជាសហគ្រិនជោគជ័យនាពេលអនាគត។

សៀវភៅនេះ ថ្វីដ្បិតតែបានបង្កប់នូវបច្ចេកទេសវិទ្យាសាស្ត្រ ប៉ុន្តែការនិពន្ធ ឬសរសេររបៀបជាការណែនាំឱ្យអនុវត្តតាម សម្រាប់ចិញ្ចឹម ថែទាំ បង្ការ ការពារជំងឺ និងគ្រប់គ្រងហិរញ្ញវត្ថុ ដោយសរសេរឱ្យខ្លីៗ ងាយយល់ មានលម្អ ដោយរូបភាពចំនួន២៨រូប ការបង្ហាញនូវរូបមន្តចំណី ការផ្សំចំណី វិធីកត់ត្រាងាយយកទៅអនុវត្ត

ដែលខ្ញុំយល់ថា អានហើយអាចទៅប្រតិបត្តិបាន។

សៀវភៅនេះជាសៀវភៅទី៧ ដែលបានបោះពុម្ព និងជាស្នាដៃបោះពុម្ពផ្សាយការងារវិទ្យាសាស្ត្រផ្នែកសុខភាពសត្វ និងផលិតកម្មសត្វទី២៩ របស់ខ្ញុំ។ បន្ថែមពីឯកសារដែលបានបោះពុម្ពផ្សាយរួចហើយ ខ្ញុំសង្ឃឹមថា សៀវភៅ "ណែនាំស្ដីពីការចិញ្ចឹមមាន់ពូជក្នុងស្រុកសម្រាប់ភ្ញាស់យកកូន និង/ឬយកសាច់ ជាលក្ខណៈពាណិជ្ជកម្មខ្នាតតូចក្នុងជួរកសិករ" នេះ នឹងជាវិភាគទានបញ្ញាញាណ បទពិសោធន៍ និងការចែករំលែកចំណេះដឹងតិចតួចរបស់ខ្ញុំមួយទៀត ជូនដល់ប្រជាជនកម្ពុជាដែលខ្ញុំគោរព និងជាទីស្រឡាញ់យ៉ាងជ្រាលជ្រៅ។

**បណ្ឌិត សួន សុធឿន**

**បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ**

**សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំជាអ្នកនិពន្ធសៀវភៅនេះ សូមធ្វើការថ្លែងអំណរគុណចំពោះ:

១. លោក **ជាង សារិទ្ធ** បច្ចុប្បន្នជាអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ ដែលយល់ព្រមពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារបច្ចេកទេសក្នុងសៀវភៅនេះ និងលោក **ម៉េង សុជី** បច្ចុប្បន្នជាអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ ដែលយល់ព្រមអានសៀវភៅនេះពីដើមដល់ចប់ ដើម្បីផ្តល់យោបល់ផ្នែកបច្ចេកទេស និងផ្តល់យោបល់លើការរៀបរៀង ការសរសេរដើម្បីធ្វើឱ្យងាយអាន ងាយយល់ និងដែលអានហើយ អាចយកទៅអនុវត្តបាន នាការបោះពុម្ពផ្សាយលើកទី១។

២. លោក លោកស្រី ដែលបាននឹងកំពុងដឹកនាំ អនុវត្ត និងសម្របសម្រួលគម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ នៃខេត្តត្បូងឃ្មុំ តាកែវ និងកំពង់ឆ្នាំង។

៣. ឯកឧត្តម **តាន់ ផាណារ៉ា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដែលគាំទ្រគម្រោង ព្រមទាំងជួយសម្របសម្រួលធ្វើឱ្យគម្រោងអនុវត្តបានយ៉ាងរលូន។

៤. ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានរៀបចំឱ្យមានគម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រនេះ។

តាមរយៈគម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ ដែលគាំទ្រថវិកាដោយរាជរដ្ឋាភិបាលនិងប្រជាជនជប៉ុន និងដោយមានការគាំទ្រពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វក្នុងការអនុវត្តគម្រោង និងផ្តល់ការអនុញ្ញាតឱ្យបោះពុម្ពសៀវភៅនេះ។ ដោយ

សារគម្រោងនេះ ខ្ញុំមានឱកាសធ្វើការផ្ទៀងផ្ទាត់ទ្រឹស្តីវិទ្យាសាស្ត្រ បច្ចេកទេស ជាមួយការអនុវត្តជាក់ស្តែងជាមួយកសិករ ដើម្បីឱ្យប្រាកដថា ការណែនាំក្នុងសៀវភៅនេះ អាចយកទៅអនុវត្តបានប្រកបដោយជោគជ័យ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**បណ្ឌិត សួន សុធឿន**

**បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ**

**សមាជិកបម្រុងរាជបណ្ឌិត្យសភាកម្ពុជា**

## ១. ហេតុអ្វីត្រូវចាប់យកមុខរបរចិញ្ចឹមមាន់ពូជក្នុងស្រុក?

បច្ចុប្បន្ន ប្រទេសកម្ពុជាមានការអភិវឌ្ឍ រីកចម្រើនយ៉ាងឆាប់រហ័ស ក្នុបផ្សំនិងសមាហរណកម្មអាស៊ាន និងជាមួយពិភពលោកកាន់តែស៊ីជម្រៅ សកម្មឡើង។ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ច បានបង្កើតនូវការងារជាច្រើនដល់ប្រជាពលរដ្ឋខ្មែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏កសិករនិងប្រជាពលរដ្ឋនៅតាមជនបទមួយចំនួន នៅតែមិនអាចរកចំណូលបានច្រើន សម្រាប់ផ្គត់ផ្គង់តម្រូវការដែលចេះតែធំឡើង។ ក្នុងស្ថានភាពដែលការរស់នៅកាន់តែមានភាពទំនើបឡើង។។

ក្នុងចំណោមមុខរបរផ្នែកកសិកម្ម តាមការស្រាវជ្រាវបានឱ្យដឹងថា ការចិញ្ចឹមសត្វជាមុខរបរដែលមានសក្តានុពល (Katherine Ashley, 2017) ដែលអាចរកប្រាក់ចំណេញបានច្រើន ពិសេសគឺការចិញ្ចឹមមាន់ពូជក្នុងស្រុក(សួន សុធឿន ២០១៧)។

### តើមូលហេតុអ្វីទៅ បានជាគួរត្រូវចិញ្ចឹមមាន់ពូជក្នុងស្រុក?

១. មិនត្រូវការដីធំនិងទុនច្រើន។ ចំពោះការចិញ្ចឹមមាន់ដែលមានមេចំនួន ៩០-១០០ក្បាល ត្រូវការដីសម្រាប់កន្លែងចិញ្ចឹមតែ១៥០០ម៉ែត្រការ៉េ (៣០មX៥០ម) ជាមួយដើមទុនប្រមាណ ១៤ ០០០ ០០០រៀល ដែលអាចរកចំណូលបានមិនតិចជាង ១ ២០០ ០០០រៀល/ខែ។

២. មាន់ពូជក្នុងស្រុក (native chicken) មានទីផ្សារនិងតម្លៃខ្ពស់។ ប្រជាជនកម្ពុជានិយមបរិភោគសាច់មាន់ស្រុក ដោយឱ្យតម្លៃថា សាច់មានរស់ជាតិឆ្ងាញ់ មានអនាម័យ និងមានសុវត្ថិភាព ដោយសារការចិញ្ចឹមមិនប្រើប្រាស់បសុឱសថហួសប្រមាណ មិនប្រើសារធាតុជំរុញការលូតលាស់ (អ័រម៉ូន)និងមិនប្រើសារធាតុហាមឃាត់ ដែលប៉ះពាល់សុខភាពអ្នកបរិភោគ។

៣. មាន់ស្រុកអាចប្រកួតប្រជែងទីផ្សារបាន។ ក្រុមហ៊ុនចិញ្ចឹមមាន់ ឬការនាំចូលមាន់រស់ សាច់មាន់ ដែលជាពូជមាន់បង្កាត់នាំមកពីបរទេស និងចិញ្ចឹមជាលក្ខណៈអាតិផល (intensive) ផ្តល់ចំណីផ្សំស្រេច ដែលមាន់ទាំងនេះចិញ្ចឹមរយៈពេលខ្លីតែ៤៥-៥០ថ្ងៃ បានទម្ងន់១.២គក្រ ទៅ១.៥០គក្រ។ ក្រុមហ៊ុនឬអ្នកផលិតទាំងនេះមិនចិញ្ចឹមមាន់ពូជក្នុងស្រុកដែលមិនងាយធំធាត់ មានន័យថា មាន់ស្រុកមិនសូវមានការប្រកួតប្រជែង ដែលកត្តានេះ ផ្តល់និងរក្សានូវចំណែកទីផ្សារសម្រាប់កសិករ ឬប្រជាពលរដ្ឋដែលចិញ្ចឹមមាន់ពូជក្នុងស្រុក។

៤. ការចិញ្ចឹមមាន់ជាលក្ខណៈពាណិជ្ជកម្មខ្នាតតូចនេះ មិនមែនជាកិច្ចការលំបាកខ្លាំង ហើយផ្តល់ឱកាសដល់ស្ត្រីសម្រាប់ប្រកបមុខរបរនេះ។ ការពិសោធន៍ស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានស្ត្រីច្រើនជាង ៦០ភាគរយ ចាប់យកមុខរបរនេះ ក្នុងចំណោមកសិករចិញ្ចឹមមាន់បង្ហាញនៃគម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ ដែលគម្រោងនេះផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលនិងប្រជាជនជប៉ុន។

ដោយសារមូលហេតុសំខាន់ៗដូចបានរៀបរាប់ខាងលើ ការចិញ្ចឹមមាន់ពូជក្នុងស្រុក ជាមុខរបរដ៏មានសក្តានុពល អាចឱ្យកសិករឬប្រជាពលរដ្ឋខ្មែរ រកចំណូលដ៏សមរម្យ ជាពិសេសអាចរស់នៅស្រុកកំណើតរបស់ខ្លួន ដោយមិនចាំបាច់ត្រូវធ្វើចំណាកស្រុក ស្វះស្វែងរកការងារធ្វើ ដើម្បីរកប្រាក់កាសចិញ្ចឹមជីវិត។ មុខរបរចិញ្ចឹមមាន់ពូជក្នុងស្រុក ជាមួយដើមទុនដែលមិនច្រើននេះ ធ្វើឱ្យកសិករឬប្រជាពលរដ្ឋក្លាយជាអ្នកផលិត ជាម្ចាស់អាជីវកម្ម និងអាចក្លាយទៅជាអ្នកមានស្តុកស្តម្ភបានដូចគំរូដែលមានរួចមកហើយ។

# ២. បច្ចេកទេសចិញ្ចឹម

## ២.១ ការជ្រើសរើសទីកន្លែងចិញ្ចឹមមាន់

ជោគជ័យក្នុងការចិញ្ចឹមមាន់មួយផ្នែកអាស្រ័យដោយសារការជ្រើសរើសទីកន្លែងចិញ្ចឹមបានត្រឹមត្រូវ។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលត្រូវអនុវត្តៈ

- ត្រូវមានទំហំផ្ទៃដីសមស្របសម្រាប់ជាកន្លែងចិញ្ចឹម។ សម្រាប់កន្លែងចិញ្ចឹមមានមេពូជចំនួន ៩០-១០០ក្បាល កន្លែងចិញ្ចឹមត្រូវមានទំហំមិនតិចជាង ១៥០០ម៉ែត្រការ៉េ (៣០ម៉ែត្រ x ៥០ម៉ែត្រ)។ ប្រសិនបើមានផែនការពង្រីកការចិញ្ចឹមនាពេលអនាគត ត្រូវមានផ្ទៃដីទំហំធំជាងនេះ
- កន្លែងចិញ្ចឹមមាន់ ជាកន្លែងមិនលិចទឹក ឬជាកន្លែងដែលមិនដក់ទឹក
- ស្ថិតនៅឆ្ងាយពីផ្លូវធ្វើដំណើរ
- កន្លែងចិញ្ចឹមមានរបងព័ទ្ធជុំវិញ។

## ២.២ ការរៀបចំរោងនិងទ្រុងសម្រាប់ចិញ្ចឹមមាន់

តាមគោលបំណងរបស់អ្នកចិញ្ចឹម អ្នកចិញ្ចឹមអាចចិញ្ចឹមមាន់ដើម្បីផលិតកូនលក់ ឬផលិតកូនសម្រាប់លក់ និងផលិតជាមាន់សាច់ ឬចិញ្ចឹមតែមាន់សាច់ប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្តី អ្នកចិញ្ចឹមត្រូវរៀបចំរោងនិងទ្រុងសម្រាប់ចិញ្ចឹម តាមការណែនាំដូចខាងក្រោម។

រោងនិងទ្រុងមាន់ក្នុងសៀវភៅនេះរួមមានៈ ក/ទ្រុងមេ-បាសម្រាប់ឱ្យមាន់ពង ខ/ទ្រុងសម្រាប់ថែទាំកូនមាន់ទើបញាស់អាយុពី១-៧ថ្ងៃ គ/ទ្រុងកូនមាន់អាយុពី៧-២១ ឬ៣០ថ្ងៃ និង ឃ/ទ្រុងមាន់ចិញ្ចឹមយកសាច់។

### ២.២.១ រោងនិងទ្រុងចិញ្ចឹមមាន់សម្រាប់ភ្ញាស់លក់កូន

**ក/រោងនិងទ្រុងមេ-បាសម្រាប់ឱ្យមាន់ពង** (សម្រាប់មេ៩០ក្បាល និងឈ្មោល១៥ក្បាល)

**ក១.ទំហំរោងនិងទ្រុង:** បណ្ដោយ១៧ម៉ែត្រ ទទឹង៨ម៉ែត្រ(១៧មx៨ម)ដោយប្រក់ដំបូលតែ១៧x៤ម។ នៅសងខាងរោងទំហំ ១៧មx(២ម+២ម) មិនប្រក់ដំបូលទេ ទុកជាទីធ្លាសម្រាប់មាន់លេង(រូបទី១ ៣ ៦ ៧ ៨ ៩ ១០ ១១ និង១២)។

រោងខណ្ឌជា១៦ទ្រុង(ម្ខាង៧ទ្រុងទំហំ២មx៤ម និងទ្រុងចំនួន២ ស្ថិតនៅផ្នែកខាងចុងនៃរោង ជាទ្រុងដែលមានទំហំ៣មx៤ម)។ ទ្រុងចំនួន១៤ ទំហំ៨ម៉ែត្រការ៉េ និងទ្រុងចំនួន១ទៀតដែលនៅខាងចុងនៃរោងមានទំហំ១២ម៉ែត្រការ៉េ សម្រាប់ចិញ្ចឹមមាន់ចំនួន៧ក្បាល (មេ៦ក្បាលនិងឈ្មោល១ក្បាល រូបទី៥) ទ្រុងដែលនៅសល់១ទៀត ទំហំ១២ម៉ែត្រការ៉េ ទុកសម្រាប់ដាក់កូនមាន់ទើបញាស់។ ទ្រុង១បែកជា២ផ្នែក: ផ្នែកសម្រាប់មាន់ពងឬសម្បុក(២មx២ម)និងកន្លែងជ្រក(រូបទី៤) និងផ្នែកទីធ្លាសម្រាប់មាន់ចេញលេង(២មx២ម)(រូបទី៧និង៨) លើកលែងទ្រុងចំនួន២ស្ថិតនៅផ្នែកខាងចុងនៃរោងដែលមានទំហំធំជាង។ ទ្រុងនីមួយៗមានទ្វារសម្រាប់ចូល-ចេញ។




រូបទី១: គំនូសប្លង់រោងចិញ្ចឹមមាន់ (មើលចំពីមុខ)

សម្គាល់: A និង D- ទីធ្លាសម្រាប់មាន់លេង

B និង C- ជម្រក/កន្លែងមាន់រស់នៅ/សម្បុក


បណ្ឌិត ស្វន សុធឿន បណ្ឌិតវិទ្យាសាស្ត្រពេទ្យសត្វ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)



រូបទី២: រោងចិញ្ចឹមមាន់ មើលចំពីមុខ



រូបទី៣: រោងចិញ្ចឹមមាន់ មើលចំពីមុខ



រូបទី៤៖ រោងចិញ្ចឹមមាន់ចែកជា១៦ទ្រុង

ផ្នែកសម្រាប់មាន់ពងនិងជម្រក(២មx២ម)



រូបទី៥៖ ទ្រុងនីមួយៗមានមេ៦ក្បាល

និងឈ្មោល១ក្បាល

### ក២. សំណង់រោងនិងទ្រុង

ផ្នែកជម្រកនិងសម្បុកមាន់៖

- រោងសង់បណ្តោយថ្ងៃ
- គ្រោងរបស់រោងធ្វើពីដែក ប្រក់ស័ង្កសីក្រាស់ និងទ្រាប់ដោយក្រដាសកាតុងក្រាស់ ឬក្រដាសអាលុយមីញ៉ូមមួយជាន់ទៀតការពារកុំឱ្យក្តៅខ្លាំង
- ជញ្ជាំងរោងរៀបឥដ្ឋពីដីកម្ពស់៤០-៥០សង់ទីម៉ែត្រ។ ផ្នែកខាងលើតភ្ជាប់ពីជញ្ជាំងឥដ្ឋ ពាសសំណាញ់ដែកទល់ដំបូល(រូបទី២ ៣និង៤)
- កម្រាលរោង ទ្រុងត្រូវក្រាលដោយស៊ីម៉ង់ ឬក្រាលអង្កាមដែលមានលាយកំបោរសសម្រាប់សម្លាប់មេរោគ(រូបទី៤)។

ផ្នែកទីធ្លាសម្រាប់មាន់ចេញលេង៖

- ទ្រុងនីមួយៗនៃទីធ្លាសម្រាប់មាន់ដែលតភ្ជាប់ពីទ្រុងជម្រកមាន់និងសម្រាប់មាន់ពង ខណ្ឌដោយបន្ទះឬស្សីឬអាចរៀបឥដ្ឋកម្ពស់៤០-៥០សង់ទីម៉ែត្រ ហើយផ្នែកខាងលើបន្ទះឫស្សីឬឥដ្ឋ ព័ទ្ធដោយសំណាញ់កម្ពស់២ម៉ែត្រ ការពារកុំឱ្យមាន់ចេញ(រូបទី៦ ៧ និង៨)។

### ១/ទ្រុងសម្រាប់ថែទាំកូនមាន់ទើបញាស់អាយុពី១-៧ថ្ងៃ

មេមាន់ចំនួន៩០ក្បាល ជាមធ្យមអាចផលិតកូនបានចំនួន៤៥០ក្បាល/ខែ ឬ ១១២ក្បាល/សប្តាហ៍។ មេមាន់ផ្តល់ស៊ុតមិនព្រមៗគ្នានោះទេ ប៉ុន្តែទោះជាយ៉ាងនេះក្តីអាចប្រមូលស៊ុតយកទៅភ្ញាស់ក្នុងរវាង១សប្តាហ៍ម្តង ១ខែភ្ញាស់៤លើក ដោយផ្តល់កូន៤លើកដែរ/ខែ)។

**១១.ទំហំទ្រុង:** ទ្រុងកូនមាន់ដែលទើបយកចេញពីទូភ្ញាស់ មានបណ្តោយ២ម៉ែត្រ ទទឹង១ម៉ែត្រ និងកម្ពស់០.៥ម៉ែត្រ(២ម៉ែត្រx១ម៉ែត្រx០.៥ម៉ែត្រ) ខណ្ឌជា២: ១ម៉ែត្រx១ម៉ែត្រ ដែលអាចផ្ទុកកូនមាន់ចំនួន១០០ក្បាល សង់ខ្ពស់ផុតពីដី។ ទ្រុងកូនមាន់នេះស្ថិតនៅខាងចុងនៃរោងមាន់(រូបទី១៣)។

**១២.សំណង់ទ្រុង:** មេធ្វើពីដែក ព័ទ្ធវិញដោយសំណាញ់លួស ដែលបាំងដោយ

ក្រដាសសំបកកេស ឬបាំងដោយបន្ទះក្តារ នៅចំកណ្តាលទ្រុងមានអំពូលភ្លើងពណ៌ថ្ងៃ ថាមពល៧៥-១០០វ៉ាត់ សម្រាប់កម្តៅកូនមាន់ បាតទ្រុងក្រាលអង្កាម។ អាចធ្វើទ្រុងពីឈើ ឫស្សី ឬសម្ភារៈផ្សេងៗទៀតដែលអាចរកបាន ប៉ុន្តែត្រូវរក្សាឱ្យបាននូវបទដ្ឋានបច្ចេកទេសដូចបានរៀបរាប់។ ត្រូវរក្សាសីតុណ្ហភាពក្នុងទ្រុងកូនមាន់នេះពី៣០-៣៣អង្សាសេ។ ត្រូវមានទែរម៉ូម៉ែត្រសម្រាប់វាស់សីតុណ្ហភាព(រូបទី២៤)។

**ក/ ទ្រុងកូនមាន់អាយុពី៧-២១ឬ៣០ថ្ងៃ**

ដោយសារតែកូនមាន់ដែលភ្ញាស់មានចំនួន១១២ក្បាល/សប្តាហ៍ ហើយត្រូវចិញ្ចឹមរហូតដល់អាយុ២១ថ្ងៃឬ៣០ថ្ងៃទើបលក់ ត្រូវមានទ្រុងដាក់កូនមាន់ទាំងនេះតាមអាយុរបស់វា។

***គ១. ទំហំទ្រុង:*** ទ្រុងបណ្តោយ៣.០ម៉ែត្រ ទទឹង១.២០ម៉ែត្រ និងកម្ពស់០.៥ម៉ែត្រ ដែលខណ្ឌជា៣ប្លុក សម្រាប់ដាក់កូនមាន់ដែលមានអាយុខុសៗគ្នា។

***គ.២. សំណង់ទ្រុង:*** សំណង់អនុវត្តដូចការសាងសង់ទ្រុងកូនមាន់អាយុពី១-៧ថ្ងៃដែរ លើកលែងតែទ្រុងកូនមាន់អាយុពី៧-២១ថ្ងៃឬ៣០ថ្ងៃ បាំងដោយសំណាញ់លួសព្រោះមិនសូវត្រូវការកម្តៅដូចកូនមាន់ទើបញាស់ ប៉ុន្តែទោះបីយ៉ាងនេះក្តី ចំកណ្តាលទ្រុងនីមួយៗ ត្រូវមានអំពូលកម្តៅថាមពល៣០-៤០វ៉ាត់ ដែលរក្សាសីតុណ្ហភាពក្នុងទ្រុងពី ២៥-៣០អង្សាសេ។ បាតទ្រុងក្រាលអង្កាម មានស្នូកចំណី និងប្រដាប់ដាក់ទឹកឱ្យមាន់ផឹក(រូបទី១៤ និង១៥)។

### ២.២.២ ទ្រុងចិញ្ចឹមមាន់សម្រាប់ភ្ញាស់កូនដើម្បីចិញ្ចឹមមាន់សាច់

ការចិញ្ចឹមមាន់យកសាច់អាចប្រព្រឹត្តទៅដោយទិញកូនមាន់មកចិញ្ចឹម ប៉ុន្តែជាការល្អប្រសិនបើចិញ្ចឹមមេដើម្បីភ្ញាស់យកកូន ហើយបន្តចិញ្ចឹមកូនមាន់ទាំងនោះរហូតដល់ទំងន់ ១.២គក្រ-១.៥គក្រ ដើម្បីលក់ជាមាន់សាច់។ មូលហេតុដែលណែនាំឱ្យចិញ្ចឹមមេភ្ញាស់យកកូន ហើយបន្តចិញ្ចឹមកូនយកសាច់គឺដោយសារតែៈ ក/ចំណេញ


បណ្ឌិត សួន សុធឿន បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)

ច្រើនជាងទិញកូនយកមកចិញ្ចឹម និង ខ/ធានានិរន្តភាពក្នុងការចិញ្ចឹម ព្រោះពេលខ្លះ បើមិនមានផែនការច្បាស់លាស់ ឬទិញកូនមាន់មិនបាន នោះការផលិតមិនបានតាមផែនការ ដែលធ្វើឱ្យចំណូលមិនទៀងទាត់។

**ក/ទ្រុងមាន់ចិញ្ចឹមយកសាច់(មេចំនួន៤៨ក្បាល ឈ្មោល៨ក្បាល និងកូនចិញ្ចឹមយកសាច់២០០-២៣០ក្បាល/ខែ)**

មេចំនួន៤៨ក្បាល អាចផ្តល់មាន់សាច់ប្រមាណ២០០-២៣០ក្បាល/ខែ។ ដើម្បីទទួលបានលទ្ធផលនេះ ត្រូវរៀបចំដូចខាងក្រោម៖

***ក១.ទំហំរោងនិងទ្រុង៖*** ទំហំនិងការសាងសង់អនុវត្តដូចគ្នានឹងរោង ទ្រុងមាន់ចិញ្ចឹមមាន់ភ្ញាស់កូនលក់ ដោយរោងបណ្តោយ១៧ម៉ែត្រ ទទឹង៨ម៉ែត្រ(១៧មx៨ម) ដោយប្រក់ដំបូលតែ១៧x៤ម។ នៅសងខាងទ្រុង១៧មx(២ម+២ម) មិនប្រក់ដំបូលទេ ទុកជាទីធ្លាសម្រាប់មាន់លេង(រូបទី១-៣ និង៧-១២)។ រោងឬទ្រុងមួយចំហៀងដែលមាន៨ប្រលោះសម្រាប់ចិញ្ចឹមមេ មួយចំហៀងទៀត យក៧ប្រលោះសម្រាប់ចិញ្ចឹមកូនយកសាច់និង១ប្រលោះទៀត (ទំហំ៣ម៉ែត្រx៤ម៉ែត្រ)ទុកសម្រាប់កូនមាន់អាយុពី១ថ្ងៃដល់៣០ថ្ងៃ។ សម្រាប់ចិញ្ចឹមមាន់សាច់ ១ម៉ែត្រការ៉េចិញ្ចឹមមាន់ចំនួន១០ក្បាល។

***ក២.សំណង់រោងនិងទ្រុង៖***

អនុវត្តដូចការសាងសង់សំណង់សម្រាប់ចិញ្ចឹមមាន់ភ្ញាស់យកកូនដែរ។



រូបទី៦៖ រោងចិញ្ចឹមមាន់មើលពីចម្ងាយ



រូបទី៧: ផ្នែកទីធ្លាសម្រាប់មាន់ចេញលេង ១ទ្រុងទំហំ(២មx២ម)



រូបទី៨: ផ្នែកទីធ្លាសម្រាប់មាន់ចេញលេង ១ទ្រុងទំហំ(២មx២ម)



រូបទី៩៖ ទីធ្លាសម្រាប់មាន់ចេញលេង ព័ទ្ធដោយលួស



រូបទី១០៖ ទីធ្លាសម្រាប់មាន់ចេញលេង ព័ទ្ធដោយសំណាញ់



រូបទី១១៖ ផ្នែកទីធ្លាមាន់ចេញលេង អាចធ្វើជាទ្រើងកាត់បន្ថយកំដៅ



រូបទី១២៖ ផ្នែកទីធ្លាមាន់ចេញលេង មានដាំដើមឈើព័ទ្ធជុំវិញ



រូបទី១៣៖ ទ្រុងកូនមាន់ទើបញាស់ (ជញ្ជាំងបិទជិត)





រូបទី១៤៖ ទ្រុងកូនមាន់អាយុ៧-៣០ថ្ងៃ (ព័ទ្ធដោយសំណាញ់)





រូបទី១៥: ទ្រុងកូនមានអាយុ៧-៣០ថ្ងៃ
ក្រាលអង្កាម មានភ្លើងកម្តៅនិងប្រដាប់ដាក់ចំណី-ទឹក



រូបទី១៦: ទ្រុងមាន់សាច់ ចិញ្ចឹម១០ក្បាល/ម៉ែត្រការ៉េ

## ២.៣ ឧបករណ៍ សម្ភារៈ ចាំបាច់សម្រាប់ចិញ្ចឹម និងភ្ញាស់

ឧបករណ៍ សម្ភារៈ ចាំបាច់សម្រាប់ចិញ្ចឹមរួមមាន៖

ក/ ទូភ្ញាស់

ខ/ ម៉ាស៊ីនកិនចំណី

គ/ ម៉ាស៊ីនហាន់បន្លែ

ឃ/ ប្រដាប់ដាក់ចំណីឬស្នូកចំណី

ង/ ប្រដាប់ដាក់ទឹកឬក្បាលបឺត

ច/ ឆ្នើរនិងសម្បុកមាន់

ឆ/ ភ្លើងបំភ្លឺនិងប្រដាប់វាស់សីតុណ្ហភាព (ទែរម៉ូម៉ែត្រ)។

### ក/ ទូភ្ញាស់

ទូភ្ញាស់ដើរតួនាទីសំខាន់ណាស់ ក្នុងការចិញ្ចឹមមាន់បែបអាជីវកម្មខ្នាតតូចដែលមានមេមាន់ចាប់ពី៩០ក្បាលឡើងទៅ។ អ្នកចិញ្ចឹមមិនអាចពឹងផ្អែកទុកឱ្យមេមាន់ក្រាបដើម្បីភ្ញាស់កូនឡើយ ព្រោះផលិតកម្មយឺត និងផលិតភាពទាប។ ទូភ្ញាស់មានច្រើនយ៉ាង ច្រើនបែប ច្រើនប្រភព និងសមត្ថភាពផលិត ទំហំផលិត ឬភ្ញាស់ខុសៗគ្នា។ ថ្វីត្បិតតែអ្នកចិញ្ចឹមតែងតែគិតពីតម្លៃទូជាចម្បង ប៉ុន្តែគុណភាពរបស់ទូភ្ញាស់ជាកត្តាចំបង ដែលធ្វើឱ្យផលិតកម្មមានដំណើរការ និងទទួលនូវផលចំណេញ។ ទូភ្ញាស់ដែលល្អគឺជាទូភ្ញាស់ដែលស៊ុតញាស់ មានអត្រាខ្ពស់រហូតដល់ច្រើនជាង ៨៥ភាគរយ ងាយស្រួលប្រើ មានទែរម៉ូម៉ែត្រសម្រាប់វាស់កំដៅ និងប្រដាប់វាស់សំណើម ឬជាទូស្វ័យប្រវត្តដែលបង្វិលស៊ុត រក្សាសីតុណ្ហភាព និងសំណើមដោយខ្លួនឯង (រូបទី១៧ និង១៨)។



រូបទី១៧: ទូភ្ញាស់ចំណុះ១០៥០គ្រាប់ (មាន៦ផ្នើរ)



រូបទី១៨: ទូភ្ញាស់មាន៤ផ្នើរ ១ផ្នើរដាក់ស៊ុតបាន១៥៦គ្រាប់

ឬអាចភ្ញាស់កូនបាន១៥៦កូន/សា(សប្តាហ៏)

## ខ/ម៉ាស៊ីនកិនចំណី

ដើម្បីកាត់បន្ថយថ្លៃដើមផលិត អ្នកចិញ្ចឹមត្រូវផលិតចំណីដោយខ្លួនឯងជាចំណីដែលមានគុណភាព អនាម័យ មានសារធាតុចិញ្ចឹមគ្រប់គ្រាន់តាមតម្រូវការរបស់មាន់តាមប្រភេទអាយុ និងមានតម្លៃថោក។ ដោយហេតុនេះហើយ ដើម្បីផលិតចំណីមាន់ដោយខ្លួនឯង អ្នកចិញ្ចឹមគួរត្រូវមានម៉ាស៊ីនកិនចំណីខ្នាតតូចមួយគ្រឿងសម្រាប់កិនលាយចំណី។ ម៉ាស៊ីនកិនចំណីនេះមានលក់នៅទីផ្សារ (រូបទី១៩)។

## គ/ម៉ាស៊ីនហាន់បន្លែ

ចំពោះការចិញ្ចឹមមាន់ដែលមានមេចាប់៩០ក្បាល ដូចសរសេរក្នុងសៀវភៅនេះ គួរត្រូវមានម៉ាស៊ីនហាន់បន្លែ ព្រោះតម្រូវការបន្លែសម្រាប់លាយជាមួយចំណីផ្តល់ឱ្យមាន់ក៏មានបរិមាណច្រើន។ ដើម្បីចំណេញពេលវេលា អ្នកចិញ្ចឹមអាចគួរទិញម៉ាស៊ីនកាត់ឬហាន់បន្លែខ្នាតតូចមួយគ្រឿង ដែលម៉ាស៊ីនកាត់ឬហាន់បន្លែនេះ ជាប្រភេទម៉ូទ័រភ្លើ អាចរកទិញបាននៅទីផ្សារ (រូបទី២០)។



រូបទី១៩: ម៉ាស៊ីនកិនចំណី



រូបទី២០: ម៉ាស៊ីនហាន់បន្លែ

### ឃ/ ប្រដាប់ដាក់ចំណីឬស្នូកចំណី

ប្រដាប់ដាក់ចំណីឬស្នូកចំណីឱ្យមាន់ស៊ី។ អាចទិញស្នូកចំណីឬប្រដាប់ដាក់ចំណីឱ្យមាន់ស៊ី ដែលឧបករណ៍នេះមានដាក់លក់ជាច្រើនប្រភេទនៅទីផ្សារ (រូបទី២១- A)។ អាចច្នៃឬផលិតស្នូកចំណីឬប្រដាប់ដាក់ចំណីឱ្យមាន់ស៊ីដោយខ្លួនឯងបាន (រូបទី២១-B)។

### ង/ ប្រដាប់ដាក់ទឹកឬក្បាលបឺត

ប្រដាប់ដាក់ទឹកឱ្យមាន់ផឹក។ ឧបករណ៍នេះមានលក់នៅទីផ្សារ (រូបទី២២) ឬអាចច្នៃធ្វើដោយខ្លួនឯងបាន។ បច្ចុប្បន្នមានលក់ប្រដាប់ឱ្យមាន់បឺតដែលមិនចាំបាច់ត្រូវផ្លាស់ប្តូរទឹក មិនកំពប់ទឹកនាំឱ្យសើមកន្លែងរស់នៅរបស់មាន់ មានអនាម័យនិងសន្សំសំចៃ (រូបទី២៣)។







រូបទី២១: ប្រដាប់ដាក់/ ស្នូកចំណី អាចទិញពីផ្សារឬច្នៃដោយខ្លួនឯង



រូបទី២២៖ ប្រដាប់ដាក់ទឹក ឱ្យមាន់ផឹក



រូបទី២៣៖ ក្បាលបឺតសម្រាប់ឱ្យមាន់ផឹកទឹក




រូបទី២៤៖ ទែរម៉ូម៉ែត្រសម្រាប់វាស់សីតុណ្ហភាព

### ច/ផ្ទើរនិងសម្បុក

ផ្ទើរនិងសម្បុកឱ្យមាន់ពង។ ផ្ទើរសម្រាប់ដាក់សម្បុកឱ្យមាន់ពងត្រូវមានកម្ពស់ ១.២០-១.៤០សង់ទីម៉ែត្រ។ អាចប្រើប្រាស់បង្គី កញ្ជើ ធ្វើជាសម្បុកដោយក្រាលចំបើងឬអាចប្រើប្រាស់សម្ភារៈផ្សេងៗទៀតតាមការចង់បានរបស់អ្នកចិញ្ចឹម។ ក្នុង១ទ្រុង គួរដាក់៣-៤សម្បុក។

ឆ/ ភ្លើងបំភ្លឺនិងប្រដាប់វាស់សីតុណ្ហភាព

ភ្លើងបំភ្លឺនិងប្រដាប់វាស់សីតុណ្ហភាពកម្ដៅក្នុងទ្រុង។ នៅទ្រុងមាន់គួរមានភ្លើងបំភ្លឺនៅពេលយប់ និងគួរព្យួរទែរម៉ូម៉ែត្រ(រូបទី២៤)សម្រាប់វាស់សីតុណ្ហភាពនៅក្នុងទ្រុងមាន់។ ប្រើអំពូលភ្លើងពណ៌ថ្ងៃ អំពូលដែលមានអនុភាព៤០វ៉ាត់។

**ចំណុចត្រូវចងចាំ:**

- ទ្រុងត្រូវស្ងួត
- មានខ្យល់អាកាសល្អ ប៉ុន្តែមិនត្រូវទទួលនូវខ្យល់ខ្លាំង
- សីតុណ្ហភាពក្នុងទ្រុងស្ថិតនៅចន្លោះ២០-២៥អង្សាសេ។
- គួរមានដាំដើមឈើចំងាយប្រមាណ៥ម៉ែត្រនៅជុំវិញទ្រុង ដែលជួយបន្ថយកម្ដៅនៅរដូវប្រាំងដែលសីតុណ្ហភាពក្ដៅខ្លាំង និងចំពោះរដូវវស្សា ឬរដូវរងាដែលមានខ្យល់ខ្លាំង គួរមានផ្ទាំងកៅស៊ូ សំបកបាវបាំងជុំវិញទ្រុង។

## ២.៤ ការជ្រើសរើសពូជមាន់សម្រាប់ចិញ្ចឹម

ក្នុងសៀវភៅនេះ ណែនាំឱ្យចិញ្ចឹមមាន់ពូជក្នុងស្រុក មូលហេតុះ

- មានតម្រូវការទីផ្សារខ្ពស់ ប្រជាជននិយមបរិភោគ
- មានតម្លៃខ្ពស់ជាងមាន់ សាច់មាន់នាំចូល ពូជនាំចូលមកចិញ្ចឹម ឬមាន់ពូជដែលបង្កាត់(មាន់បង្កាត់)
- ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ
- អភិរក្សពូជក្នុងស្រុក។

ពូជមាន់ក្នុងស្រុក (Native chicken) មានច្រើនប្រភេទមានមាឌធំនិងទម្ងន់ធ្ងន់។ លក្ខណៈរួមសំខាន់ៗសម្គាល់ថាជាពូជល្អ មានដូចខាងក្រោមះ

**ក/មេសម្រាប់ធ្វើពូជៈ** មេមានលក្ខណៈដូចខាងក្រោមះ

- មានមាឌធំ ទំងន់ចាប់ពី១.៥០គក្រឡើងទៅ (រូបទី២៥)
- ផ្តល់ពងច្រើន ពងធំ ហើយពងរយៈពេលយូរ។ មេផ្តល់ពងច្រើនជាង ១២គ្រាប់/សា
- ផ្តល់ពង៦-៧ដង/ឆ្នាំ ឬច្រើនជាងនេះរិតតែល្អ
- ជើងពណ៌លឿង(រមៀត) សាច់លឿង
- រោមភ្លឺ មុខក្រហម ភ្នែកភ្លឺថ្លា ក្លៀវក្លា
- មានសុខភាពល្អ មិនធ្លាប់កើតជំងឺ ឬមិនទិញពីប្រភពដែលកន្លែងចិញ្ចឹមធ្លាប់កើតជំងឺ។

**ខ/បាសម្រាប់ធ្វើពូជៈ** ទិញមាន់ឈ្មោលជំទង់ ឬទិញកូនពីបាដែលមានលក្ខណៈដូចខាងក្រោមះ

- បាមានទម្ងន់មិនតិចជាង២.៥គក្រ (រូបទី២៦)
- ពូកែជាន់មេនិងក្លៀវក្លា
- អត្រាបង្កកំណើតឬញាស់របស់ស៊ុតខ្ពស់
- ជើងពណ៌លឿង(រមៀត) សាច់លឿង

- រោមភ្លឺ មុខក្រហម ភ្នែកភ្លឺថ្លា ក្លៀវក្លា
- មានសុខភាពល្អ មិនធ្លាប់កើតជំងឺ ឬមិនទិញពីប្រភពដែលកន្លែងចិញ្ចឹមធ្លាប់កើតជំងឺ។

**ក/ <u>ការជ្រើសរើសកូនមាន់សម្រាប់បំប៉នយកសាច់</u>**

- កូនមាន់មានអាយុពី២០ថ្ងៃឡើងទៅ។ អាចជ្រើសរើសកូនមាន់អាយុពី១-៧ថ្ងៃបាន ប៉ុន្តែអត្រាងាប់ខ្ពស់ជាងកូនមាន់ដែលមានអាយុច្រើនហើយ
- សុខភាពល្អ រោមភ្លឺ រោមត្រសុះ ក្លៀវក្លា រហ័សរហួន ភ្នែកភ្លឺថ្លា ថ្លោស គូទស្ងួត
- បានចាក់ថ្នាំការពារជំងឺសំខាន់ៗរួចហើយ(មើលផ្នែកចាក់ថ្នាំការពារ)។



រូបទី២៥: លក្ខណៈមាន់មេ ជ្រើសរើសសម្រាប់ធ្វើពូជ


បណ្ឌិត **សួន សុធឿន** បណ្ឌិតវិទ្យាសាស្ត្របសុពេទ្យ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)



រូបទី២៦៖ ពូជមាន់ស្រុក ជ្រើសរើសសម្រាប់ធ្វើពូជ

## ២.៥ ចំណី ការផ្សំចំណី ទឹក និងការផ្តល់ចំណី-ទឹក

ចំណីផ្តល់ឱ្យមាន់គ្រប់វ័យ ត្រូវមានគុណភាពល្អ ផ្តល់ឱ្យមាន់ស៊ីគ្រប់គ្រាន់ មានអនាម័យ មិនផ្ទុកនូវជាតិពុល និងជាពិសេស មានជីវជាតិគ្រប់គ្រាន់ សម្រាប់តម្រូវការរបស់មាន់។ ចំណីល្អធ្វើឱ្យមាន់ធំលូតលាស់បានលឿន និង មាន់មានសុខភាពល្អ។ មាន់ត្រូវការចំណីដែលមានថាមពលប្រូតេអ៊ីន (ជាតិសាច់) វីតាមីន និងសារធាតុរ៉ែ។

### ២.៥.១ ចំណី

ក/**ចំណីផ្តល់នូវថាមពល** មានដូចជាពោត ស្រូវ ចុងអង្ករ កន្ទក់ ម្សៅសណ្តែកសៀង កាកសណ្តែកសៀង ដំឡូងឬម្សៅដំឡូង ស្ករ ខ្លាញ់ឬប្រេង។ល។

ខ/**ចំណីផ្តល់នូវប្រូតេអ៊ីន(ជាតិសាច់)** មានដូចជាត្រី ត្រីសម្រាប់ហាលធ្វើចំណី កាកសំណល់មួយផ្នែកនៃត្រីដូចជាក្បាលត្រី ម្សៅត្រី ម្សៅសាច់ ម្សៅបង្គា សណ្តែកសៀង ម្សៅសណ្តែកសៀង ជន្ទេន កាកដូង ម្សៅស្លឹកក្ធម្ពទេស (Leucaena) ស្លឹកស្មៅស្តាយឡូ (Stylo) ស្លឹកទ្រើចាន់ធារ៉ា (Trichantheara)។ល។

គ/**វីតាមីន** មាននៅក្នុងសមាសធាតុដែលយកមកផ្សំជាចំណី ឬនៅក្នុងបន្លែ ប៉ុន្តែជាទូទៅមិនគ្រប់គ្រាន់ទេ។ ត្រូវទិញវីតាមីនមកលាយបន្ថែមដើម្បីឱ្យ គ្រប់តាមតម្រូវការ។ វីតាមីនដែលលក់នៅទីផ្សារ អាចផ្សំជាមួយប្រេម៉ិច ឬជាទម្រង់ផ្សេងៗ។

ឃ/**ចំណីផ្តល់នូវជាតិរ៉ែ** សម្បូរនៅក្នុងសំបកខ្យង-ខ្ចៅ អំបិល ម្សៅឆ្អឹង ឬត្រូវបានលក់ក្នុងទម្រង់ជាប្រេម៉ិច ដែលអាចរកទិញបាននៅទីផ្សារ។

កម្រិតនៃតម្រូវការសារធាតុចិញ្ចឹមសម្រាប់កូនមាន់ មាន់សាច់ និងមេមាន់ពង ឬ បង្ហាញក្នុងតារាងខាងក្រោមៈ

| សារធាតុ | កូនមាន់អាយុ ១-៣០ថ្ងៃ | មាន់សាច់ | មេពងនិងឬ |
|---|---|---|---|
| ប្រូតេអ៊ីន % | ២១-២២ | ១៨-២០ | ១៧-១៨ |
| ជាតិខ្លាញ់ % | ៣-៤ | ៤ | ៣.០ |
| ជាតិសៃលុយឡូស % | ៣-៥ | ៣-៥ | ៤-៦ |
| កាល់ស្យូម % | ០.៨-១.២ | ១ | ២.៥-៣.២៥ |
| ផូស្វ័រ % | ០.៧០ | ០.៧០ | ០.៦-០.៧ |
| អំបិល % | ០.៣-០.៥ | ០.៣-០.៥ | ០.៥ |

## ២.៥.២ ការផ្សំចំណី

### ក/ ចំណីកូនមាន់(អាយុ១-៣០ថ្ងៃ)

កូនមាន់ត្រូវការចំណីដែលមានប្រូតេអ៊ីនខ្ពស់(ជាតិសាច់) ដើម្បីលូតលាស់។ កម្រិតភាគរយប្រូតេអ៊ីនដែលមានក្នុងចំណីគឺ២១-២២.០ភាគរយ។ អ្នកចិញ្ចឹមអាចផ្សំចំណីសម្រាប់កូនមាន់ពីវត្ថុធាតុដើម និងបរិមាណដូចមានណែនាំខាងក្រោមៈ

| លរ | វត្ថុធាតុដើម | ប្រូតេអ៊ីន (CP %) | តម្លៃ(រៀល /គក្រ) | សម្រាប់កូនមាន់ | | |
|---|---|---|---|---|---|---|
| | | | | តម្រូវការ (ក្រ) | ប្រូតេអ៊ីន (CP %) | តម្លៃ(រៀល /គក្រ) |
| ១ | កន្ទក់ | ១១ | - | ៣០ | ៣.៣ | - |
| ២ | ចុងអង្ករ | ៩ | - | ២០ | ១.៨ | - |
| ៣ | ពោតក្រហម | ១០ | - | ១៦ | ១.៦ | - |
| ៤ | សណ្តែកសៀង | ៤៥ | - | ១៦ | ៧.២ | - |
| ៥ | ម្សៅត្រី | ៥០ | - | ១៦ | ៨ | - |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | ប្រេងឆា | ០ | - | ១ | ០ | - |
| ៧ | សំបកខ្យង | ០ | - | ១ | ០ | - |
| ៨ | ប្រេម៊ិច | ០ | - | ០.៣ | ០ | - |
| ៩ | អំបិល | ០ | - | ០.២ | ០ | - |
| | | | | ១០០.៥ | ២១.៩០ | |
| សម្រាប់កូនមាន់ | | | | | ២២.០ | |

(រូមមន្ត លោក ជៀង សារិទ្ធ អ្នកជំនាញផ្នែកចិញ្ចឹមសត្វ)

**ខ/ចំណីសម្រាប់មាន់ធំនិងមេមាន់**

កម្រិតភាគរយជាតិសាច់ដែលមានក្នុងចំណីគឺ១៨.០ភាគរយ។ អ្នកចិញ្ចឹមអាចផ្សំចំណីសម្រាប់មាន់ពីវត្ថុធាតុដើម និងបរិមាណដូចមានណែនាំខាងក្រោមៈ

| លរ | វត្ថុធាតុដើម | ប្រូតេអ៊ីន (CP %) | តម្លៃ(រៀល/គក្រ) | សម្រាប់មាន់ធំនិងមេមាន់ | | |
|---|---|---|---|---|---|---|
| | | | | តម្រូវការ (ក្រ) | ប្រូតេអ៊ីន (CP %) | តម្លៃ(រៀល/គក្រ) |
| ១ | កន្ទក់ | ១១ | - | ៣០ | ៣.៣ | - |
| ២ | ចុងអង្ករ | ៩ | - | ១៥ | ១.៣៥ | - |
| ៣ | ពោតក្រហម | ១០ | - | ១៤ | ១.៤ | - |
| ៤ | ដំឡូងមីចំណិត | ២ | - | ១០ | ០.២ | - |
| ៥ | សណ្តែកសៀង | ៤៥ | - | ១៤ | ៥.៦ | - |
| ៦ | ម្សៅត្រី | ៥០ | - | ១៣.៥ | ៦.០ | - |
| ៧ | ប្រេងឆា | ០ | - | ១ | ០ | - |
| ៨ | សំបកខ្យង | ០ | - | ២.៥ | ០ | - |
| ៩ | ប្រេម៊ិច | ០ | - | ០.៣ | ០ | - |
| ១០ | អំបិល | ០ | - | ០.២ | ០ | - |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ១០០.៥ | ១៧.៩២ | |
| សម្រាប់មាន់ធំ មេមាន់ | | | | | ១៨.០ | |

(រូបមន្ត លោក ជៀង សារិទ្ធ អ្នកជំនាញផ្នែកចិញ្ចឹមសត្វ)

**សម្គាល់:** សម្រាប់កូនមាន់ដែលត្រូវការចំណីដែលមានប្រូតេអ៊ីនខ្ពស់អាចទិញចំណីផ្សំស្រេចរបស់ក្រុមហ៊ុនផលិតចំណី។ ទោះបីជាអនុវត្តតាមរូបមន្តនេះក្តី ក៏គុណភាពចំណីអាចមានការប្រែប្រួលដោយសារបច្ចេកទេសរក្សា ស្តុកទុកវត្ថុធាតុដើម ប្រភពវត្ថុធាតុដើម ការកិន និងលាយចំណី។ល។

- ចំណីសម្រាប់កូនមាន់មិនត្រូវការជាតិខ្លាញ់លើសពី៥.០ភាគរយ។ ចំពោះមាន់ធំមិនត្រូវមានជាតិខ្លាញ់លើស៨.០ភាគរយ។
- កាល់ស្យូមក្នុងចំណីកូនមាន់ និងមាន់ជំទើរត្រូវការ១.០ភាគរយ។ មាន់ពងត្រូវការ២.៥-៣.២៥ភាគរយ
- ក្នុងចំណីត្រូវមានផូស្វ័រ០.៧ភាគរយចំពោះមាន់សាច់ មាន់ពង-០.៦-០.៦៥ភាគរយ។

### ២.៥.៣ ការផ្តល់ចំណីនិងទឹក(របបអាហារ)

**ក/ការផ្តល់ចំណីនិងទឹកសម្រាប់កូនមាន់អាយុ១-៣០ថ្ងៃ**

- ជាមធ្យមកូនមាន់១ក្បាលស៊ីចំណី៣០ក្រាម/ថ្ងៃ
- ត្រូវដាក់ចំណីឱ្យកូនមាន់ស៊ី៣-៤ដង/ថ្ងៃដើម្បីឱ្យកូនមាន់ស៊ីឱ្យបានច្រើន
- ទឹកផ្តល់ឱ្យផឹកដោយសេរី ប៉ុន្តែទឹកត្រូវមានអនាម័យ ស្អាត និងមានជាប្រចាំ។

**ខ/ការផ្តល់ចំណីមាន់ជំទង់(អាយុ៣០-៦០ថ្ងៃ)**

- ជាមធ្យមមាន់ជំទង់១ក្បាលស៊ីចំណី៦០ក្រាម/ថ្ងៃ
- ត្រូវដាក់ចំណីឱ្យកូនមាន់ស៊ី២-៣ដង/ថ្ងៃ
- ទឹកផ្តល់ឱ្យផឹកដោយសេរី ប៉ុន្តែទឹកត្រូវមានអនាម័យ ស្អាត និងមាន

ជាប្រចាំ។

គ/ **ការផ្តល់ចំណីមាន់ធំ(អាយុ៦០-១២០ថ្ងៃ)**

- ជាមធ្យមមាន់ធំ១ក្បាលស៊ីចំណី១២០ក្រាម-១៥០ក្រាម/ថ្ងៃ
- ត្រូវដាក់ចំណីឱ្យមាន់ស៊ី២-៣ដង/ថ្ងៃ
- ទឹកផ្តល់ឱ្យផឹកដោយសេរី ប៉ុន្តែទឹកត្រូវមានអនាម័យ ស្អាត និងមានជាប្រចាំ។

ឃ/ **ការផ្តល់ចំណីសម្រាប់មេ-បា**

- ជាមធ្យមមាន់មេឬបា១ក្បាល ស៊ីចំណី១៥០ក្រាម-២០០ក្រាម/ថ្ងៃ
- ត្រូវដាក់ចំណីឱ្យមាន់ស៊ី២-៣ដង/ថ្ងៃ
- ទឹកផ្តល់ឱ្យផឹកដោយសេរី ប៉ុន្តែទឹកត្រូវមានអនាម័យ ស្អាត និងមានជាប្រចាំ។

**សម្គាល់:**

- ចំណីត្រូវបន្ថែមបន្លែ (ត្រកួន ស្លឹកក្តម្ពទេស ស្លឹកទ្រីចាន់ធារ៉ា ស្មៅស្តាយឡូ។ល។)
- តាមដានមើលការស៊ីចំណីរបស់មាន់។ បើមាន់ចឹកគ្នា មាន់ស៊ីស៊ុតក្នុងសម្បុក អាចជាសញ្ញាថា ខ្វះជីវជាតិក្នុងចំណី ដូចជាខ្វះជាតិកាល់ស្យូម។ ករណីដូចនេះត្រូវប្រឹក្សាជាមួយអ្នកជំនាញ។
- មាន់ថយពង សំបកពងទន់ ស្តើង ចឹកពងស៊ីខ្លួនឯង ជាសញ្ញាថាខ្វះជាតិកាល់ស្យូម ដូចនេះត្រូវបន្ថែមម្សៅខ្ចៅខ្យង លៀស ក្នុងចំណី។

## ២.៦ ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់និងការភ្ញាស់ស៊ុត

ស៊ុតមាន់ត្រូវប្រមូលជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃទី៦(មិនទុកឱ្យហួស៧ថ្ងៃ) ស៊ុតទាំងនោះត្រូវភ្ញាស់ជាមួយគ្នាតែ១សា (ប្រមាណជាង១០០គ្រាប់/សា) បន្ទាប់មកប្រមូលជាបន្តបន្ទាប់ ហើយដាក់ភ្ញាស់ជាមួយគ្នាសម្រាប់សាទី២ និងអនុវត្តជាបន្តបន្ទាប់ ដើម្បីផលិតកូនបាន១ដងក្នុង១សប្តាហ៍។ អនុវត្តដូចនេះអាចប្រើប្រាស់ទូភ្ញាស់ចំណុះ ៥០០គ្រាប់បាន សម្រាប់ការចិញ្ចឹមមេ ៩០-១០០ក្បាល ដែលអាចលក់កូនមាន់រៀងរាល់សប្តាហ៍។

### ក/ <u>ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់</u>

- ស៊ុតត្រូវប្រមូលពីសម្បុករៀងរាល់ថ្ងៃ
- ប្រមូលស៊ុតពីសម្បុក ទុកតែ១-២គ្រាប់ដែលទើបពងថ្មីៗ
- រើសទុកសម្រាប់ភ្ញាស់តែស៊ុតណាដែលល្អ សំបកស៊ុតរឹងល្អ មិនពៀច មិនតូចខុសប្រក្រតី មិនប្រេះស្រាំ
- ទម្ងន់ស៊ុតពី៣៥-៥០ក្រាម
- ដាក់ស៊ុតក្នុងប្រដាប់ដាក់ស៊ុត(រូបទី២៧) ដាក់ផ្នែកធំនៃស៊ុតនៅខាងលើ។



រូបទី២៧: ការរៀបចំ ទុកដាក់ស៊ុតដើម្បីភ្ញាស់

## ខ/ការសម្អាតនិងថែរក្សាស៊ុតដើម្បីភ្ញាស់

- ករណីស៊ុតប្រឡាក់អាចមិ៍មាន់ក្នុងសម្បុក ត្រូវជូតសម្អាត ប៉ុន្តែជូតដោយថ្នមៗ
- ស៊ុតដែលប្រមូលបានត្រូវយកមករក្សាទុកនៅកន្លែងដែលមានអាកាសធាតុសមស្រប ពោលគឺសីតុណ្ហភាពពី២០-២៥អង្សាសេ និងកន្លែងដែលមានសំណើមពី៥៥-៦៥%។

## គ/ការភ្ញាស់ស៊ុត

ការចិញ្ចឹមបែបពាណិជ្ជកម្មខ្នាតតូចក្នុងជួរកសិករនេះណែនាំឱ្យអ្នកចិញ្ចឹមមានទូសម្រាប់ភ្ញាស់ដែលមានចំណុះមិនតិចជាង៥០០គ្រាប់។ លក្ខណៈសំខាន់ៗរបស់ទូភ្ញាស់បានបរិយាយរួចហើយ។ ការភ្ញាស់ស៊ុតមានរយៈពេល២១ថ្ងៃ។ ការភ្ញាស់ស៊ុតត្រូវអនុវត្តដូចខាងក្រោមៈ

- ទូភ្ញាស់ស៊ុតត្រូវដាក់នៅកន្លែងដែលមានខ្យល់អាកាសល្អ មិនហាប់ កន្លែងដែលមិនក្តៅ
- មុនដាក់ស៊ុតចូលដើម្បីភ្ញាស់ ទូត្រូវសម្អាត
- ដាក់ទឹកក្នុងថាសទឹកនៅបាតទូភ្ញាស់ឱ្យបានគ្រប់គ្រាន់ (រូបទី២៨)
- តម្រៀបស៊ុតដាក់ផ្នែកដែលធំ(ឃ្លុបខ្យល់)នៅខាងលើ ក្នុងថាសសម្រាប់ភ្ញាស់។ ជាទូទៅ មាន៤-៦ថាស/ទូ ដែលថាសនីមួយៗចំណុះលើសពី១០០គ្រាប់ (គួរទិញប្រភេទទូដែលមានលក្ខណៈដូចបរិយាយនេះ)
- សីតុណ្ហភាពក្នុងទូភ្ញាស់ពី៣៧.៥-៣៧.៨អង្សាសេ សំណើម៦០-៧០អង្សាសេ
- ស៊ុតត្រូវបានបង្វិល៣-៤ដង/ថ្ងៃ បង្វិលរយៈពេល១៨ថ្ងៃ
- ពីថ្ងៃទី១៨-ថ្ងៃទី២១ មិនត្រូវបង្វិលស៊ុតទៀតឡើយ។ ស៊ុតត្រូវយកមកដាក់ថ្នើរខាងក្រោមបំផុត ព្រោះចាប់ពីថ្ងៃទី២០ ស៊ុតចាប់ផ្តើមញាស់ និងថ្ងៃទី២១ ស៊ុតញាស់ស្ទើរតែ១០០%ហើយ។



រូបទី២៨៖ ទូភ្ញាស់ស្វ័យប្រវត្ត

(ដាក់ទឹកក្នុងថាសទឹកនៅបាតទូ)

**ចំណុចត្រូវចងចាំ៖**

- ស៊ុតដែលដាក់ភ្ញាស់ជាស៊ុតមិនប្រេះស្រាំ
- ដាក់ស៊ុតក្នុងកេស ឬកម្តៅដោយអំពូលភ្លើង១០-១៥នាទីមុនដាក់ចូលទូភ្ញាស់
- ចាប់ពីសប្តាហ៍ទី១(ថ្ងៃទី៧)ត្រូវឆ្លុះមើលការបង្កកំណើតរបស់អំប្រីយ៉ុងក្នុងស៊ុត។ ក្នុងស៊ុតឃើញមានសរសៃឈាម។
- សប្តាហ៍ទី២(ថ្ងៃទី១៤)ត្រូវបន្តតាមដានការវិវឌ្ឍការបង្កកំណើតរបស់អំប្រីយ៉ុង។ ឃើញមានសរសៃឈាម និងដុំពណ៌ខ្មៅប៉ុនម្រាមដៃ ដែលនេះជាអំប្រីយ៉ុងដែលនឹងចេះតែធំបន្តិចម្តងៗ
- ស៊ុតដែលខូច ត្រូវយកចេញពីទូភ្ញាស់។

## ២.៧ ការថែរក្សាកូនមាន់អាយុ១-៣០ថ្ងៃ

- រក្សាកូនមាន់ក្នុងទូភ្ញាស់ប្រមាណ២៤ម៉ោង ក្រោយពេលញាស់ បន្ទាប់មក យកកូនមាន់ដាក់ក្នុងទ្រុងរក្សាកូនមាន់ទើបញាស់។
- ទ្រុងកូនមាន់ទើបញាស់ បាតទ្រុងត្រូវក្រាលអង្កាម
- មានអំពូលដែលមានថាមពលពី៧៥-១០០វ៉ាត់ សម្រាប់កម្តៅកូនមាន់។ បើគ្មានអំពូលភ្លើង អាចប្រើភ្លមដាក់ធ្យូងសម្រាប់កម្តៅ ដោយរក្សាសីតុណ្ហភាពពី៣១-៣៥អង្សាសេ
- កូនមាន់អាយុកាន់តែច្រើន កូនមាន់កាន់តែធំ ត្រូវបន្ថយកម្តៅក្នុងទ្រុង។
- កូនមាន់អាយុពី៧ថ្ងៃឡើងទៅ ត្រូវដាក់ក្នុងទ្រុងដែលមានខ្យល់ចេញចូល មិនដាក់ក្នុងទ្រុងបិទជិតទៀតទេ។

## ២.៨ ការថែទាំទូទៅ ការគ្រប់គ្រងការចិញ្ចឹម អនាម័យ និងជីវសុវត្ថិភាព

ការថែទាំ ការគ្រប់គ្រងការចិញ្ចឹមល្អ ការចិញ្ចឹមមានអនាម័យ និងការអនុវត្ត ជីវសុវត្ថិភាពល្អ អាចបញ្ចៀសបានពីជំងឺ មាន់មានសុខភាពល្អ ឆាប់ធំធាត់ សាច់មានគុណភាព និងសុវត្ថិភាពសម្រាប់អ្នកបរិភោគ មិនសូវចំណាយប្រាក់កាស ទទួលផលចំណេញច្រើន និងរក្សាបាននូវទីផ្សារសម្រាប់លក់ផលិតផល។

- ក្នុងទ្រុងទំហំ៤ម៉ែត្រការ៉េ(២មX២ម) ចិញ្ចឹមមេ-បាចំនួន៧ក្បាល ក្នុងនោះ មេ៦ក្បាល និងបា១ក្បាល។ សមាមាត្រមេ-បានេះ អាចឱ្យមានអត្រាបង្កកំណើតខ្ពស់
- កូនមាន់គួរដាក់ក្នុងទ្រុងចំណុះ១០០ក្បាល/ម៉ែត្រការ៉េ
- មាន់សាច់គួរចិញ្ចឹមក្នុងទ្រុងចំណុះ១០ក្បាល/ម៉ែត្រការ៉េ
- មេមាន់ដែលមិនសូវផ្តល់ពង(ពងតិចជាង៦០គ្រាប់/ឆ្នាំ) ត្រូវជម្រុះចោល
- មេមាន់ដែលឧស្សាហ៍ជល់ ចឹកជាមួយមេមាន់ដទៃនៅក្នុងទ្រុងជាមួយគ្នា កូនញាស់មិនសូវមានសុខភាពល្អ ត្រូវជម្រុះចោល

- មាន់ឈ្មោល(បា) ដែលមិនសូវពូកែជាន់មេ ឬអត្រាបង្កកំណើតស៊ុតទាប កូនញាស់មិនសូវមានសុខភាពល្អ ត្រូវជម្រុះចោល
- មាន់មេនិងបា ដែលមានអាយុលើសពី៣៦ខែ ត្រូវជម្រុះចោល
- កូនមាន់ មាន់ដែលមានសុខភាពមិនល្អ ពិការ ក្រិន ត្រូវជម្រុះចោល
- ទ្រុងត្រូវស្ងួត សីតុណ្ហភាពក្នុងទ្រុងមិនប្រែប្រួលដែលរក្សាក្នុងរង្វង់២០-២៥ អង្សាសេ
- សំណើមស្ថិតនៅចន្លោះ៧០-៧៥%
- មិនរងនូវខ្យល់បោកបក់ខ្លាំង
- ត្រូវសម្អាតទ្រុងជាប្រចាំ។

## ២.៩ ការបង្ការនិងការការពារជំងឺ

- ការពារដើម្បីកុំឱ្យជំងឺពីខាងក្រៅចូលក្នុងកន្លែងចិញ្ចឹម
- បង្កើនភាពធន់របស់មាន់ៈ ថែទាំឱ្យល្អ ផ្តល់ចំណីនិងទឹកឱ្យបានគ្រប់គ្រាន់ និងតាមតម្រូវការលូតលាស់របស់មាន់
- មាន់ត្រូវចាក់ថ្នាំការពារជំងឺឆ្លងសំខាន់ៗ និងទៀងទាត់
- បាញ់ថ្នាំសម្លាប់មេរោគ១ខែម្តង។ ថ្នាំសម្លាប់មេរោគត្រូវជាប្រភេទថ្នាំដែលអាចសម្លាប់ពពួកបាក់តេរី ពពួកវីរុស និងពពួកផ្សិត។ ប្រភេទថ្នាំដែលគេធ្លាប់ស្គាល់និងធ្លាប់ប្រើមានប្រសិទ្ធភាពដូចជា TH4 (glutaraldehyde and quartermary ammonium) ឬ Formaldehyde, Phenolic compounds ឬ Sodium hydroxide ។

### ២.៩.១ ជីវសុវត្ថិភាព

ខាងក្រោមនេះជាវិធានជីវសុវត្ថិភាព១០ចំណុច ក្នុងការបង្ការជំងឺមាន់ដែលត្រូវអនុវត្តៈ

១. មាន់នាំមកចិញ្ចឹម ត្រូវស្គាល់ប្រភព ដែលធានាថាគ្មានជំងឺ។

២. ត្រូវចាក់ថ្នាំការពារតាមពេលវេលាកំណត់ និងតាមកម្រិតឱ្យប្រើប្រាស់។

ប្រើប្រាស់ថ្នាំការពារដែលរក្សាទុកដាក់ត្រឹមត្រូវតាមបច្ចេកទេស។

៣. ហាមអ្នកក្រៅ ជាពិសេសឈ្មួញប្រមូលទិញមាន់ ចូលក្នុងបរិវេណចិញ្ចឹម ចូលក្នុងទ្រុង ឬប៉ះពាល់ឧបករណ៍ សម្ភារៈ ឬមាន់ដែលចិញ្ចឹម។

៤. មិនត្រូវឱ្យមាន់ជទៃឬមាន់អ្នកជិតខាង មកនៅលាយឡំនិងរកស៊ីជាមួយគ្នាក្នុងកន្លែងចិញ្ចឹមមាន់ ព្រោះអាចនាំមកនូវការឆ្លងរាលដាលជំងឺ។ មាន់គួរដាក់ចិញ្ចឹមទៅតាមក្រុមអាយុរបស់វា។

៥. កន្លែងចិញ្ចឹមត្រូវមានកំបោរស ឬល្បាយថ្នាំសម្លាប់មេរោគ ដាក់នៅមាត់ច្រកឬទ្វារដែលឆ្លងកាត់កន្លែងចិញ្ចឹម។ ពេលចូល-ចេញពីកន្លែងចិញ្ចឹមត្រូវជ្រលក់ស្បែកជើងក្នុងល្បាយថ្នាំសម្លាប់មេរោគ ដើម្បីសម្លាប់ឬកាត់បន្ថយមេរោគ ឆ្លងចូល-ចេញពីកន្លែងចិញ្ចឹម។ ថ្នាំសម្លាប់មេរោគរួមមានៈ

- កំបោរស។ កំបោរសប្រើសម្រាប់កន្លែងឆ្លងកាត់ បាចនៅកន្លែងចិញ្ចឹម ឬលាយជាមួយអង្កាម ក្រាលកន្លែងចិញ្ចឹម
- ថ្នាំសម្លាប់មេរោគ ដូចជា TH4 លាយតាមបច្ចេកទេសសម្រាប់បាញ់សម្លាប់មេរោគ ប្រើ១ខែម្តង ឬនៅពេលបញ្ចេញមាន់មួយសា។។

៦. ទ្រុងចិញ្ចឹមត្រូវស្ងួត មានពន្លឺគ្រប់គ្រាន់ និងមានខ្យល់ចេញ-ចូល។

៧. ត្រូវផ្តល់ទឹកស្អាតគ្រប់គ្រាន់ ប្តូរទឹករៀងរាល់ថ្ងៃ(ករណីប្រើស្នូកទឹក)។

៨. ត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់និងមានគុណភាពតាមរូបមន្តដែលបានណែនាំ។

៩. ត្រូវសម្អាតទ្រុងរៀងរាល់សប្តាហ៍។

១០. មាន់ឈឺត្រូវយកចេញពីទ្រុង ករណីចាំបាច់ត្រូវសម្លាប់ចោល រួចដុតឬកប់។

## ២.៩.២ ជំងឺសំខាន់ៗដែលជួបប្រទះ

### ២.៩.២.១ ជំងឺអាសន្នរោគ (Fowl Cholera/Avian Pasteurellosis)

ជំងឺអាសន្នរោគជាជំងឺឆ្លងកើតលើមាន់ បង្កដោយបាក់តេរីប្រភេទ Pasteurella multocida។ រោគសញ្ញាជាទូទៅមានដូចជា មាន់ងាប់ភ្លាមៗ គ្រុនមិនស៊ីចំណី សំកុក ហូរសារធាតុរាវពីមាត់ រាគអាចម៍ពីពណ៌សទៅខៀវ រោមបះ ដង្កើមញាប់ សាច់ស្បែកឬឡើងខៀវនៅពេលងាប់ សរីរាង្គខាងក្នុងដូចជាថ្លើម លំពែងហើម រីកធំហើយមានស្នាមលឿងឬសៗ។ អត្រាងាប់ខ្ពស់។

ការចម្លងជំងឺតាមរយៈលាមកមាន់ឈឺ ប៉ះពាល់មាន់ឈឺ ឆ្លងតាមចំណី ទឹក ឧបករណ៍ សម្ភារៈដែលយកពីកន្លែងមាន់ឈឺ មនុស្ស សត្វប៉ះពាល់មាន់ឈឺ ហើយចូលមកកន្លែងចិញ្ចឹមមាន់។

វិធីការពារ:

- ចាក់វ៉ាក់សាំង
- អាយុមាន់ត្រូវចាក់ មាន់អាយុ៦០ថ្ងៃឬយ៉ាងយូរ៧៥ថ្ងៃ
- ចាក់សាច់ដុំទ្រូង កម្រិតចាក់តាមប្រភេទថ្នាំ
- មានភាពស៊ាំ៦ខែ។ ប្រភពវ៉ាក់សាំងពីវៀតណាម ថៃឡង់ដ៍។ល។

ការព្យាបាល:

- មិនគួរទុកមាន់ឈឺដើម្បីធ្វើការព្យាបាលទេ សត្វឈឺត្រូវជម្រុះចោល
- ករណីចង់ព្យាបាល អាចប្រើអង់ទីប៊ីយូទិក។

### ២.៩.២.២ ជំងឺញូកាស (Newcastle Disease)

ជំងឺញូកាសជាជំងឺឆ្លងស្រួចស្រាល់កើតលើមាន់ បង្កដោយវីរុសប្រភេទ Avian paramyxovirus។ រោគសញ្ញាជាទូទៅមានដូចជា មិនស៊ីចំណី សំកុក រោមបះ ដង្ហក់ ហូរសារធាតុរាវពីច្រមុះ ក្អក រោគសញ្ញាប្រព័ន្ធប្រសាទ ពិការជើងនិងស្លាប ងាប់ដោយទំលាក់ស្លាបទាំងសងខាង រមួលក្បាលនិងរមួលក "តែរ៉េ" រាគ លាមកពណ៌បៃតង។ ករណីជំងឺស្រួចស្រាល់ខ្លាំង សត្វស្លាប់ដោយមិនបង្ហាញរោគសញ្ញា

អត្រាងាប់ខ្ពស់។

ការចម្លងជំងឺតាមរយៈលាមកមាន់ឈឺ ប៉ះពាល់មាន់ឈឺ ឆ្លងតាមចំណី ទឹក ឧបករណ៍ សម្ភារៈដែលយកពីកន្លែងមាន់ឈឺ មនុស្ស សត្វប៉ះពាល់មាន់ឈឺ ហើយចូលមកកន្លែងចិញ្ចឹមមាន់ និងតាមរយៈខ្យល់។

វិធីការពារ:

- ចាក់វ៉ាក់សាំង
- ចាក់វ៉ាក់សាំង២លើក ករណីប្រើវ៉ាក់សាំងញូកាសអេហ្វ (F) និងអឹម (M):

លើកទី១ បន្តក់វ៉ាក់សាំងប្រភេទអេហ្វ (F) ចំពោះមាន់អាយុ៣-៧ថ្ងៃ បន្តក់តាមរន្ធច្រមុះឬភ្នែក១-២តំណក់/ក្បាល

លើកទី២ វ៉ាក់សាំងប្រភេទអឹម (M) ចំពោះមាន់អាយុ២-៣ខែ ចាក់សាច់ដុំ

- មានភាពស៊ាំ៦-១២ខែ។ ប្រភពវ៉ាក់សាំងពីវៀតណាម ថៃឡង់ដ៏។ល។
- អាចប្រើវ៉ាក់សាំង១បែបទៀត I-2 ជាវ៉ាក់សាំងរស់ មិនចាំបាច់រក្សាទុកក្នុងទូទឹកកកដូចវ៉ាក់សាំងដទៃរហូតដល់២ខែ។ វ៉ាក់សាំងនេះប្រើដោយបន្តក់ភ្នែក រំលឹកឡើងវិញរៀងរាល់៤-៥ខែម្តង។ វ៉ាក់សាំងនេះមានតម្លៃថោក។ ប្រទេសវៀតណាមមានផលិតវ៉ាក់សាំងនេះដែរ។ ប្រទេសផលិតវ៉ាក់សាំងនេះដំបូងគេគឺប្រទេសអូស្ត្រាលី។

### ២.៩.២.៣ ជំងឺអុត (Fowl Pox)

ជំងឺអុតជាជំងឺឆ្លង កើតលើមាន់បង្កដោយវីរុសពួក Avipox virus។ រោគសញ្ញាជាទូទៅមានដូចជាមានក្រម៉ដុំៗកើតនៅសិរ យ៉ារ ត្របកភ្នែក ចំពុះ ជើងផ្នែកខាងក្នុងនៃស្លាប ជុំវិញរន្ធអាក់ ក្នុងមាត់ បំពង់សំឡេង បំពង់ខ្យល់។ ដុំក្រម៉អុតនេះ បើកើតចំភ្នែកធ្វើឱ្យខ្វាក់ ស៊ីចំណី ផឹកទឹកមិនកើត បើនៅក្នុងមាត់ បំពង់សំឡេង បំពង់ខ្យល់ ធ្វើឱ្យថប់ដង្ហើមនិងស៊ីចំណីដោយពិបាក ជំងឺបណ្តាលឱ្យសត្វក្រិន ផលិតស៊ុតថយ ឬអាចងាប់។

ជំងឺត្រូវបានចម្លងតាមរយៈមូស ឬសុច ហើយកើតលើមាន់គ្រប់វ័យ។

វិធីការពារ:

- ចាក់វ៉ាក់សាំង
- អាយុមាន់ត្រូវចាក់វ៉ាក់ពី១៤ថ្ងៃឡើងទៅ
- វិធីចាក់វ៉ាក់សាំងគឺចាក់នៅសន្ទះស្លាបដោយប្រើប្រដាប់ចាក់ឬជួសវ៉ាក់សាំង
- ប្រើខ្ទឹមសបុកឱ្យម៉ត់ ដាក់លាយក្នុងទឹកឱ្យមាន់ផឹក ឬបញ្ច្រាកខ្ទឹមស ដោយដំឱ្យទក់ រួចបេះបញ្ច្រាកមាន់
- ករណីមានមាន់ឈឺ គួរជម្រុះចោល ដើម្បីជៀសវាងការឆ្លងរាលដាលបន្ត។

ការព្យាបាល:

- ជំងឺបង្កដោយវីរុសមិនអាចព្យាបាលបានទេ
- ករណីមិនជម្រុះចោល អាចព្យាបាលដំបៅដែលកើតលើមាន់ ដូចជាប្រើ Methylene blue 2%, Iodine ។ល។ លាបលើដំបៅ លាបលើក្រម៉ុអុតនោះ។

## ២.៩.២.៤ ជំងឺផ្តាសាយបក្សី (Avian Influenza/Bird Flu)

ជំងឺផ្តាសាយបក្សីជាជំងឺឆ្លងខ្លាំងក្លា បណ្តាលពីវីរុស ពួក Avian Influenza virus។ រោគសញ្ញាមានដូចជា មាន់សំកុកមិនស៊ីចំណី មិនផឹកទឹក ក្អកហៀរសំបោរ រោមបះ រាគខៀវ សញ្ញាប្រព័ន្ធប្រសាទ ហើមក្បាល ហើមមុខ ក្បាល-សិរ យ៉ពណ៌ខៀវរួចប្រែជាស្វាយ ហើមជើង របកស្រកា ជើងពណ៌ខៀវ ឬស្វាយ អត្រាងាប់លឿននិងខ្ពស់។

ការចម្លងជំងឺតាមរយៈលាមកមាន់ឈឺ ប៉ះពាល់មាន់ឈឺ ឆ្លងតាមចំណី ទឹក ឧបករណ៍ឬសម្ភារៈដែលយកពីកន្លែងមាន់ឈឺ មនុស្ស សត្វប៉ះពាល់មាន់ឈឺ ហើយចូលមកកន្លែងចិញ្ចឹមមាន់ តាមរយៈខ្យល់ សត្វស្លាបព្រៃ។

វិធីការពារ:

- អនុវត្តវិធានជីវសុវត្ថិភាព
- ចំពោះការចាក់វ៉ាក់សាំងការពារ: ថ្វីបើមានប្រទេសមួយចំនួនអនុញ្ញាតឱ្យប្រើប្រាស់វ៉ាក់សាំងការពារជំងឺនេះ ប៉ុន្តែនៅប្រទេសកម្ពុជាមិនអនុញ្ញាតឱ្យប្រើប្រាស់

រ៉ាក់សាំងទេ។

### ២.៩.២.៥ ជំងឺបង្កដោយព្រូនមូល (Ascaridiosis)

ជំងឺបង្កដោយព្រូនមូលអាស្ការីស បណ្ដាលពីព្រូនមូលប្រភេទ Ascaris Galli ។ ជំងឺបណ្ដាលឱ្យមាន់ស្គម ក្រិន មិនងាយធំ ដោយសារព្រូនធ្វើឱ្យមាន់ខ្វះជីវជាតិ មាន់ងាប់ករណីព្រូនមានចំនួនច្រើន ឬបណ្ដាលមកពីស្ទះពោះវៀន មាន់ស្លេកស្លាំង រោមបះ មេមាន់ថយពង ចុះទម្ងន់។

ការចម្លងជំងឺដោយសារស៊ីចំណី ផឹកទឹក ដែលមានស៊ុតព្រូននៅលាយឡំជាមួយ។

វិធីការពារ:

- កន្លែងចិញ្ចឹមត្រូវមានអនាម័យ
- មានកម្មវិធីទម្លាក់ព្រូនលើមាន់ដែលចិញ្ចឹម។

ការព្យាបាល:

- ប្រើថ្នាំទម្លាក់ព្រូនដូចជា Albendazole, Fenbendazole, Piperazine, Levamizole ។ ថ្នាំទាំងនេះមានតម្លៃថោក ងាយរកទិញតាមកន្លែងលក់ចំណី ថ្នាំសត្វ មានប្រភពពីប្រទេសវៀតណាម ថៃឡង់ដ៍។ល។ វិធីប្រើ មើលលើសំបកថ្នាំឬតាមការណែនាំរបស់អ្នកជំនាញ។ ជាទូទៅប្រើដោយលាយជាមួយចំណី។

### ២.៩.២.៦ បរាសីតខាងក្រៅ(ស្រមើលនិងចៃ)

បរាសីតដូចជាស្រមើលនិងចៃ ធ្វើឱ្យមាន់មិនសូវលូតលាស់និងធំលឿនទេហើយខាំមនុស្សដែលប៉ះពាល់ជាមួយមាន់ទាំងនោះ ឬចូលកន្លែងចិញ្ចឹម។ កន្លែងចិញ្ចឹមដែលមានអនាម័យ ឧស្សាហ៍បោសសម្អាត មិនសូវមានបរាសីតទាំងនេះទេ។

វិធីការពារ:

- ឧស្សាហ៍បោសសម្អាតទ្រុង កន្លែងចិញ្ចឹមមាន់
- កន្លែងចិញ្ចឹមត្រូវមានអនាម័យ

- ក្នុងសម្បុកមាន់ដាក់ថ្នាំខ្លាំងឬលាយថ្នាំខ្លាំងជាមួយទឹក បាចនៅកន្លែងចិញ្ចឹម ដើម្បីបំបាត់បរាសីតទាំងនេះ។

**កម្មវិធីចាក់វ៉ាក់សាំងមាន់**

| អាយុ | អាសន្នរោគ | ញូកាស | អុត | ទម្លាក់ព្រូន | ចៃ ស្រមើល |
|---|---|---|---|---|---|
| ៣ថ្ងៃ | - | បន្តក់រន្ធច្រមុះ បន្តក់ភ្នែក (ញូកាសអេហ្វ) | - | - | - |
| ១៤ថ្ងៃ | - | - | ចាក់សន្ទះស្លាប | - | - |
| ៦០ថ្ងៃ | ចាក់សាច់ដុំ | ចាក់សាច់ដុំ (ញូកាសអឹម) | - | - | អនាម័យ ថ្នាំជក់ លាយទឹក បាចកន្លែង ចិញ្ចឹម |
| ៩០ថ្ងៃ | | | | លាយចំណី លាយទឹក | |
| ១៨០ | | | | លាយចំណី លាយទឹក | |

- វ៉ាក់សាំង I-2 អាចបន្តក់ភ្នែកចំពោះមាន់ចាប់ពីអាយុ៣ថ្ងៃឡើងទៅ និងរំលឹកវិញរៀងរាល់ ៤-៥ខែម្តង។
- ទម្លាក់ព្រូន ចំពោះមាន់មេ-បា ៣-៦ខែ/ម្តង។
- ចៃនិងស្រមើល ត្រូវធ្វើអនាម័យជាប្រចាំ ប្រើថ្នាំជក់ដាក់ក្នុងសម្បុក និងលាយថ្នាំជក់ជាមួយទឹក បាចកន្លែងចិញ្ចឹម។

### ២.៩.២.៧ ជំងឺផ្សេងៗទៀត

សម្រាប់ការចិញ្ចឹមមាន់ពូជក្នុងស្រុក ដែលចិញ្ចឹមតាមបែបពាណិជ្ជកម្មខ្នាតតូចក្នុងជួរកសិករ ជំងឺមាន់សំខាន់ៗដែលឧស្សាហ៍ជួបប្រទះត្រូវបានរៀបរាប់រួចហើយ។ អ្នកចិញ្ចឹមមិនគួរចាក់វ៉ាក់សាំងការពារជំងឺច្រើនលើសពីនេះ ពីព្រោះត្រូវការចំណាយច្រើន ហើយមិនចាំបាច់ ប្រសិនបើអនុវត្តជីវសុវត្ថិភាពបានល្អ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សៀវភៅនេះក៏បង្ហាញនូវឈ្មោះជំងឺមួយចំនួន ដែលអាចកើតមាននៅកន្លែងចិញ្ចឹម។

ជំងឺទាំងនោះមានដូចជា ជំងឺរាគឈាមបណ្តាលពីពពួកកុកស៊ីដ្យា (Coccidiosis) ជំងឺរលាកផ្លូវដង្ហើម (Chronic Respiratory Disease) ជំងឺរាគស (Salmonellosis) ។ល។

**ជំងឺរាគឈាម (Coccidiosis)**

ជំងឺរាគឈាមជាជំងឺបណ្តាលពីបរាសីតពពួកប្រូតូសូអ៊ែកុកស៊ីដ្យា។ ជំងឺបណ្តាលឱ្យមាន់ស្គម មិនសូវមានចលនា ក្បាលសំយ៉ុង ញាក់ញ័រ រោមបះ ភ្នែកបិទ ដេកផ្ទុំគ្នា អាចមិ៍ពណ៌ក្រហមព្រឿងៗ ឬរាគលាយឈាម មានឈាមជាប់គូទ។ អត្រាងាប់ខ្ពស់ពី៥០-៧០ភាគរយ។ មាន់ដែលមិនងាប់ពីជំងឺ ក្រិន មិនងាយធំ។

វិធីការពារ:

- កន្លែងចិញ្ចឹមត្រូវមានអនាម័យ
- មានកម្មវិធីកម្ចាត់បរាសីតលើមាន់ដែលចិញ្ចឹម។

ការព្យាបាល:

- ប្រើថ្នាំដូចជា Furazolidon, Nitrofurazolidon, Furazon, Sulfaquinoxaline ឬ Sulfamethazine ។ល។

  ថ្នាំទាំងនេះអាចរកទិញតាមកន្លែងលក់ចំណី ថ្នាំសត្វ។ វិធីប្រើមើលលើសំបកថ្នាំ ឬតាមការណែនាំរបស់អ្នកជំនាញ។ ជាទូទៅ ប្រើដោយលាយជាមួយចំណី។

## ជំងឺរលាកផ្លូវដង្ហើម (Chronic Respiratory Disease)

ជំងឺរលាកផ្លូវដង្ហើមជាជំងឺបង្កដោយបាក់តេរី ប្រភេទ Mycoplasma Gallisepticum។ ជំងឺបណ្តាលឱ្យមាន់ពិបាកដកដង្ហើម មិនសូវស៊ីចំណី រលាស់ស្លាបនិងក្បាល ដកដង្ហើមចូល-ចេញឮសូរដូចកើតហឺត។ ករណីខ្លះសង្កេតឃើញមាន់ហៀរសំបោរ ហើមមុខ ចុះស្គម ក្រិននិងថយពង។ ក្រៅពីបណ្តាលឱ្យមាន់រលាកផ្លូវដង្ហើម កាលណាមានមេរោគផ្សេងទៀតឆ្លង ធ្វើឱ្យមាន់កាន់តែឈឺធ្ងន់ធ្ងរមានសភាពដុនដាបថែមទៀត។ ជំងឺអាចឆ្លងតាមសម្ភារៈដែលប្រើប្រាស់តាមរយៈស៊ុតពីសត្វដែលមានជំងឺ។

វិធីការពារ:

- កន្លែងចិញ្ចឹមត្រូវមានអនាម័យ
- អនុវត្តវិធានជីវសុវត្ថិភាព
- មិនទាន់មានវ៉ាក់សាំងការពារនៅឡើយ
- សត្វឈឺត្រូវជម្រុះចោល។

ការព្យាបាល:

- គ្មានថ្នាំព្យាបាលដែលមានប្រសិទ្ធភាពទេ។

## ជំងឺរាគស (Salmonellosis)

ជំងឺរាគសបណ្តាលមកពីបាក់តេរី Salmonella Gallinarum ច្រើនកើតលើមាន់អាយុ១០-១៥ថ្ងៃ ដោយអត្រាងាប់ខ្ពស់រហូតដល់៥០ភាគរយ។ លក្ខណៈសម្គាល់ថាមាន់កើតជំងឺ គឺកូនមាន់រាគអាចម៍ពណ៌ស ពោះធំ រោមបះ សំកុក ភ្នែកមមីផឹកទឹកច្រើន ស៊ីតិចឬមិនស៊ីចំណីតែម្តង ឬហើមសន្លាក់ជើង។ ការចម្លងជំងឺប្រព្រឹត្តទៅតាមរយៈចំណីនិងទឹកដែលមានមេរោគ តាមរយៈលាមកសត្វឈឺ។

វិធីការពារ:

- កន្លែងចិញ្ចឹមត្រូវមានអនាម័យ
- អនុវត្តវិធានជីវសុវត្ថិភាព
- សត្វឈឺត្រូវជម្រុះចោល។

ការព្យាបាល:

- ករណីធ្វើការព្យាបាល ត្រូវប្រើអង់ទីប៊ីយូទិក ដូចជា Tetracyclines, Amoxicillin, Fluoroquinolones ឬ Sulfonamide ។
- ថ្នាំទាំងនេះអាចរកទិញតាមកន្លែងលក់ចំណីថ្នាំសត្វ។ វិធីប្រើ មើលលើសំបកថ្នាំ ឬតាមការណែនាំរបស់អ្នកជំនាញ។

## ៣. ការរៀបចំអាជីវកម្មចិញ្ចឹមមាន់ខ្នាតតូច

សៀវភៅនេះ ណែនាំឱ្យចិញ្ចឹមមាន់តាមបែបពាណិជ្ជកម្មខ្នាតតូចចិញ្ចឹមមាន់ជាមុខរបរដែលមានចំណូលអាចចិញ្ចឹមជីវិត ដោយមិនចាំបាច់ទៅស្វែងរកលុយកាក់តាមរយៈការធ្វើចំណាកស្រុកទៅរកការងារ រកលុយនៅក្រៅស្រុកកំណើត។ ជោគជ័យនៃការធ្វើអាជីវកម្មចិញ្ចឹមមាន់នេះអាចកើតឡើងបានលុះណាតែអ្នកចិញ្ចឹមត្រូវ ១/ មានការសម្រេចចិត្តច្បាស់លាស់ក្នុងការធ្វើអាជីវកម្មចិញ្ចឹមមាន់ ២/ ធ្វើការវិនិយោគ ៣/ ស្វាធ្យាយក្នុងការរៀនសូត្រ ដកស្រង់យកបទពិសោធន៍លើ ការចិញ្ចឹមមាន់ ៤/ ត្រូវប្រតិបត្តិតាមតាមបច្ចេកទេស និងបទដ្ឋានដែលបរិយាយ ពន្យល់ក្នុងសៀវភៅនេះ និងជាពិសេស ៥/ចេះគ្រប់គ្រងហិរញ្ញវត្ថុ។

**សម្រាប់ការចិញ្ចឹមមាន់បែបពាណិជ្ជកម្មខ្នាតតូច ដែលរំពឹងថា អ្នកចិញ្ចឹមនឹងទទួលប្រាក់ចំណេញលើសពី ១ ២០០ ០០០រៀល/ខែ អ្នកចិញ្ចឹមត្រូវចិញ្ចឹមមាន់ពូជ ក្នុងស្រុក (Native chicken) ដែលផ្តើមពីមានមេមាន់ចំនួន៩០ក្បាល និងមាន់ឈ្មោល ១៥ក្បាល(ជា)។**

### ៣.១ ការសម្រេចចិត្តក្នុងការធ្វើអាជីវកម្មចិញ្ចឹមមាន់

ការសម្រេចចិត្តចាប់ផ្តើមអាជីវកម្មចិញ្ចឹមមាន់ជាការសំខាន់ និងធ្វើឱ្យមានជោគជ័យ។ កសិករឬអ្នកចិញ្ចឹមត្រូវធ្វើការសិក្សាស្វែងយល់តម្រូវការពីទុន ជំនាញបច្ចេកទេស ការគ្រប់គ្រង ការប្រកួតប្រជែងទីផ្សារ និងហានិភ័យដែលអាចកើតមានឡើងពីការធ្វើអាជីវកម្ម និងលទ្ធភាពចំណេញពីអាជីវកម្មនេះ ដោយសារជាមុខជំនួញ ការសម្រេចចិត្តក្នុងការចាប់យកអាជីវកម្មនេះជាការសំខាន់បំផុត។ ពេលវេលាសម្រាប់មើលថែទាំ ចិញ្ចឹមមាន់ក៏មិនត្រូវមើលរំលង ពីព្រោះបើមើល ថែទាំ និងគ្រប់គ្រងមិនដិតដល់ អាជីវកម្មនេះក៏ប្រាកដជាជួបនឹងភាពបរាជ័យជាមិនខាន។

## ៣.២ ការវិនិយោគ

ទឹកប្រាក់សម្រាប់វិនិយោគ ដែលរួមមានរោង ទ្រុង ឧបករណ៍ សម្ភារៈ។ល។ សម្រាប់ចិញ្ចឹមមាន់អស់ប្រមាណ១៤ ០០០ ០០០រៀល ឬការចំណាយតិចជាងនេះ ប្រសិនបើប្រើប្រាស់របស់ដែលមានស្រាប់ និងចេះច្នៃប្រឌិត។ រោង ទ្រុង ឧបករណ៍ សម្ភារៈមានដូចខាងក្រោមៈ

| លរ | បរិយាយ | ទំហំ/ ចំនួន/ ក្បាល | តម្លៃប្រហែល(រៀល) |
|---|---|---|---|
| | រោង (17m X 8m) | 01 | 8,000,000 |
| | ម៉ាស៊ីនភ្ញាស់(ចំណុះ៦២៤គ្រាប់) | 01 | 2,000,000 |
| | ម៉ាស៊ីនកិនចំណី | 01 | - |
| | ម៉ាស៊ីនហាន់បន្លែ | 01 | 440,000 |
| | ស្នូកចំណី/ ប្រដាប់ដាក់ចំណី | 20 | 200,000 |
| | ស្នូកទឹក/ ប្រដាប់ដាក់ទឹក/ ក្បាលបឺត | 20 | 160,000 |
| | ពូជមាន់(មេ) | 90 | 1,800,000 |
| | ពូជបា | 15 | 300,000 |
| | ចំណី វ៉ាក់សាំង ផ្សេងៗ | | 1,100,000 |
| | **សរុប** | | **14,000,000** |

## ៣.៣ ការរៀនសូត្របច្ចេកទេសនិងការគ្រប់គ្រង

កសិករឬអ្នកដែលមានបំណងចង់ចាប់យកការចិញ្ចឹមមាន់ជាមុខរបរ ត្រូវចេះបច្ចេកទេសចិញ្ចឹម និងមានចំណេះដឹងគ្រឹះគ្រប់គ្រងអាជីវកម្ម ឬគ្រប់គ្រងហិរញ្ញវត្ថុ។ ដើម្បីអាចមានចំណេះដឹងបច្ចេកទេសចិញ្ចឹមមាន់ៈ ការជ្រើសរើសពូជ ការចិញ្ចឹម ថែទាំ ផ្តល់ចំណី-ទឹក ភ្ញាស់ ការបង្ការ និងការពារជំងឺ ជីវសុវត្ថិភាព និងការគ្រប់គ្រងអាជីវកម្ម កសិករឬអ្នកចិញ្ចឹមមាន់ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលបច្ចេកទេស យ៉ាងហោចណាស់ចំនួន៣វគ្គ និងទស្សនកិច្ចសិក្សាកន្លែងចិញ្ចឹមមាន់

ដើម្បីបានឃើញផ្ទាល់នឹងភ្នែកនូវការចិញ្ចឹម របៀបចិញ្ចឹម និងផ្តល់ចំណី និងមានឱកាសបានដកស្រង់បទពិសោធន៍ពីអ្នកចិញ្ចឹមមាន់ជោគជ័យទាំងនោះ។ ចំពោះវគ្គបណ្តុះបណ្តាល ជាទូទៅ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលជាអ្នករៀបចំ ប៉ុន្តែទោះជាយ៉ាងនេះក្តី គុណភាពនៃកម្មវិធីបណ្តុះបណ្តាល គុណភាពរបស់គ្រូបង្រៀន ឬអ្នកឧទ្ទេសនាម ក៏ជាគន្លឹះជោគជ័យសម្រាប់ការចិញ្ចឹមមាន់ទាំងមូលផងដែរ។

## ៣.៤ ការប្រតិបត្តិតាមតាមបច្ចេកទេសនិងបទដ្ឋាននៃសៀវភៅនេះ

កសិករឬអ្នកចិញ្ចឹមមាន់ត្រូវធ្វើការជ្រើសរើសទីតាំង រៀបចំរោង ទ្រុងចិញ្ចឹម ជ្រើសរើសពូជមាន់ក្នុងស្រុក បច្ចេកទេសចិញ្ចឹម ថែទាំ បង្ការ និងការពារជំងឺ ក៏ដូចជាអនុវត្តវិធានជីវសុវត្ថិភាព ដូចមានសរសេរលម្អិតក្នុងសៀវភៅនេះ។ បើមិនអនុវត្តតាមការណែនាំ តាមការតម្រូវ និងតាមបទដ្ឋាននេះ កសិករឬអ្នកចិញ្ចឹមអាចនឹងមិនទទួលនូវប្រាក់ចំណូល ឬលទ្ធផលដូចបានរំពឹងទុកនេះ។

## ៣.៥ ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការចិញ្ចឹមមាន់

កសិករ ឬអ្នកចិញ្ចឹមមាន់ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលលើការធ្វើអាជីវកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ។ បន្ថែមលើសពីនេះ ត្រូវធ្វើការកត់ត្រាចំណាយនិងចំណូលលើការចិញ្ចឹមមាន់នេះ។ **ហេតុអ្វីត្រូវកត់ត្រាការចំណាយ-ចំណូលពីការចិញ្ចឹមមាន់នេះ?**

### ៣.៥.១ ការកត់ត្រាចំណាយ ចំណូល និងការគ្រប់គ្រងហិរញ្ញវត្ថុ

ការកត់ត្រាចំណាយចំណូលជាការសំខាន់បំផុតសម្រាប់ការធ្វើអាជីវកម្មចិញ្ចឹមមាន់នេះ។ ដោយសារការកត់ត្រានេះ អាចវិភាគលើប្រសិទ្ធភាពសេដ្ឋកិច្ច។ ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ ដូចជាការគ្រប់គ្រងចំណាយ ចំណូល ការសន្សំសំចៃក្នុងការចំណាយ ធ្វើឱ្យអាជីវកម្មមានការរីកចម្រើន និងមាននិរន្តរភាព។

ប្រការដែលកសិករ អ្នកចិញ្ចឹមមាន់ត្រូវយកចិត្តទុកដាក់៖

- ជារៀងរាល់ថ្ងៃ ត្រូវកត់ត្រារាល់ការចំណាយ-ចំណូល ទាក់ទងនឹងការចិញ្ចឹមមាន់នេះ
- ត្រូវបូកសរុបការចំណាយនិងចំណូលរៀងរាល់១ខែម្តង
- ត្រូវទូទាត់ការចំណាយនិងចំណូលរៀងរាល់៣ខែ ៦ខែ ៩ខែ និងសម្រាប់រយៈពេល១ឆ្នាំ
- ការទូទាត់នេះនឹងបង្ហាញពីប្រសិទ្ធភាពសេដ្ឋកិច្ច(ចំណូល)នៃការចិញ្ចឹមមាន់របស់អ្នក។

### ៣.៥.២ ការវិភាគសេដ្ឋកិច្ច

ការវិភាគសេដ្ឋកិច្ច (Costs and benefits) នេះមានន័យថា តើកសិករឬអ្នកចិញ្ចឹមមាន់បានចំណាយប៉ុន្មាន? លើអ្វីខ្លះ? សម្រាប់ផលិតកម្មនេះ ហើយតើបានទទួលលុយប៉ុន្មាន? ពីអ្វីខ្លះ និងចំណេញប៉ុន្មាន? តាមរយៈការវិភាគលើទិន្នន័យដែលកត់ត្រាជាទៀងទាត់ កសិករឬអ្នកចិញ្ចឹមអាចពិនិត្យឃើញថា ការចំណាយក្នុងមួយឯកតាមានការប្រែប្រួលទៅតាមពេលវេលា តាមរដូវកាល ហើយដូចគ្នាដែរចំពោះចំណូល។ ឧទាហរណ៍ កសិករឬអ្នកចិញ្ចឹមអាចទិញវត្ថុធាតុដើមថោកនៅរដូវដែលប្រមូលផល ឬពេលដែលសម្បូរ ទិញដុំ(ទិញក្នុងបរិមាណច្រើន) ឬត្រូវធ្វើការសន្សំសំចៃ ប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវចំណី ថ្នាំព្យាបាល វ៉ាក់សាំង និងពេលវេលា។

## ឯកសារស្រាវជ្រាវ


១. ការសិក្សាស្តីពីកសិករឆ្នើមចិញ្ចឹមមាន់ពូជក្នុងស្រុកជាមុខរបរ-លោកស្រី ពុត សុជា នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នៃគម្រោងសន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ (២០១៧)។

២. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ (២០១៥)។ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៤ទំព័រ។

៣. ផែនការជាតិរួមរបស់កម្ពុជា ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយមនុស្ស (២០០៧) ទំព័រ១៤-២៧។

៤. ជា ណោង(១៩៩៦): បច្ចេកទេសចិញ្ចឹមមាន់ ១១៧ទំព័រ។

៥. សួន សុធឿន(១៩៩៥): ប៉ារ៉ាស៊ីតសាស្ត្រ និងជំងឺបង្កដោយប៉ារ៉ាស៊ីតចំពោះសត្វស្រុកនៅកម្ពុជា ១២៧ទំព័រ។

៦. សួន សុធឿន(២០០៦): បទដ្ឋានអនុវត្តបច្ចេកវិទ្យាជម្ងឺបង្កដោយព្រូនហ្វាស្យូឡាលើគោ ក្របី និងវិធានការការពារ ២៦ទំព័រ។

៧. សួន សុធឿន(២០១០): ចំណីអាហារគោ ក្របី ២៣ទំព័រ។

៨. សួន សុធឿន(២០១២): ដំណាំចំណីសត្វ និងបច្ចេកទេសដាំដំណាំចំណីសត្វ ៥១ទំព័រ។

៩. Cencus of Agriculture of the Kingdom of Cambodia 2013(2015): National Institute of Statistics, Ministry of Planning in Collaboration with the Ministry of Agriculture, Forestry and Fisheries. December 2015.

១០. Terrestrial Animal Health Code (2017). World Organization for Animal Health, volum II

១១. Alders, R., dos Anjos, F., Bagnol, B., Fumo, A., Mata, B. and Young, M.(2002): Controlling Newcastle Disease in village chickens, ACIAR Monograph No.86, 128 pages

១២. Christopher Delgado, Mark Rosegrant, Henning Steinfeld, Simeon Ehui and Claude

Courbois(1999): Livestock to 2020. The Next Food Revolution. Page 40. International Food Policy Research Institute, USA.

១៣. Katherine Ashley(2017): Socio-economic study in cattle production in Cambodia (Household summary). Village-based biosecurity for livestock disease risk management in Cambodia. 2017.

អាស័យដ្ឋានទំនាក់ទំនងៈ បណ្ឌិត **សួន សុធឿន**
បណ្ឌិតវិទ្យាសាស្រ្តបសុពេទ្យ (PhD. in Veterinary Science)
សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា (Associate Member Royal Academy of Cambodia)
អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងជាប្រធានគម្រោង
សន្តិសុខស្បៀងសម្រាប់កសិករក្រីក្រ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ
ផ្លូវ៣៧១(សឡា) ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទៈ ០១២ ៧១៤ ៦៨២
E-mail: sothoeunsuon@gmail.com